 បោះពុម្ពនៅរោងពុម្ព ទីស្ដីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២.៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

*****

ឆ្នាំទី ៧ លេខ ១៦ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្ដីសំរេច
- សារាចរ

ផ្សាយចេញពីទីស្ដីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្ដាហ៍

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ២៤-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៩០ តែងតាំងឯកឧត្ដម ០៣ រូប ជាទីប្រឹក្សាសម្ដេច ហេង សំរិន អនុប្រធានទី១ នៃរដ្ឋសភា | ៧២៦ |
| ២៩-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៩១ តែងតាំងឯកឧត្ដម សុខ ស៊ីផាន់ណា ជារដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | ៧២៧ |
| ២៩-៤-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៩២ តែងតាំង ឯកឧត្ដម ជុំ ភាគណាល់ ជាទីប្រឹក្សាផ្ទាល់របស់សម្ដេច ហ៊ុន សែន នាយករដ្ឋមន្ត្រី | ៧២៨ |


## II- រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ៣៥ អនក្រ.បក ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ៧២៩ |
| ២៧-៤-១៩៩៩ | -អនុក្រឹត្យ លេខ ៣៦ អនក្រ.បក ស្ដីពីការគ្រប់គ្រងសំណល់រឹង | ៧៤៣ |
| ២៨-៤-១៩៩៩ | -អនុក្រឹត្យ លេខ ៣៧ អនក្រ.បក ស្ដីពីការកែសម្រួលអនុក្រឹត្យលេខ ២៩ អនក្រ.បក ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ១៩៩៨ ស្ដីពីសមាសភាព និងការប្រព្រឹត្តទៅ នៃគណៈកម្មការប្រឹក្សាការងារ | ៧៥០ |
| ៣០-៤-១៩៩៩ | -អនុក្រឹត្យ លេខ ៣៨ អនក្រ.បក ស្ដីពីការគ្រប់គ្រងនិងការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ | ៧៥២ |
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១១៩ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៧៥៨ |
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២០ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៧៥៩ |
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២១ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៧៦០ |
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ | ៧៦១ |
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៣ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ | ៧៦២ |

| | | | |
|---|---|---|---|
| ២៦-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៤ អនក្រ.តត | ស្តីពីការតែងតាំងអនុប្រធានគណៈកម្មាធិការ POW/MIA កម្ពុជា | ៧៦៣ |
| ២៧-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៥ អនក្រ.តត | ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៧៦៣ |
| ២៧-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៦ អនក្រ.តត | ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៧៦៥ |
| ២៨-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៧ អនក្រ.តត | ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៧៦៦ |
| ២៨-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៨ អនក្រ.តត | ស្តីពីការជូនមេដាយស្ថាបនាជាតិ | ៧៦៧ |
| ៣០-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១២៩ អនក្រ.តត | ស្តីពីការតែងតាំងមន្ត្រីរាជការ | ៧៦៨ |
| ៣០-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១៣០ អនក្រ.តត | ស្តីពីការតែងតាំងមន្ត្រីរាជការ | ៧៦៨ |
| ៣០-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១៣១ អនក្រ.តត | ស្តីពីការតែងតាំងមន្ត្រីរាជការ | ៧៦៩ |
| ៣០-៤-១៩៩៩ | -អនុក្រឹត្យ លេខ ១៣២ អនក្រ.តត | ស្តីពីការតែងតាំងមន្ត្រីរាជការ | ៧៧០ |

## ២-សេចក្តីសំរេច

| | | | |
|---|---|---|---|
| ២៧-៤-១៩៩៩ | -សេចក្តីសំរេច លេខ ៣៨ សសរ | ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន ឆ្លងកាត់ព្រំដែនថ្នាក់ខេត្ត | ៧៧១ |
| ២៧-៤-១៩៩៩ | -សេចក្តីសំរេច លេខ ៣៩ សសរ | ស្តីពីការផ្ទេរសិទ្ធិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ | ៧៧៣ |

# III- ភាគខាងបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និង ថាមពល

### ប្រកាស

| | | |
|---|---|---|
| ២៧-៤-១៩៩៩ | -ប្រកាស លេខ ៤៤៨ ឧក-ប្រក អនុញ្ញាតអោយក្រុមហ៊ុន ហ្វូ ឆេង ហ្គាម៉ិន តំណាងដោយលោក JI ZHAN KUN សញ្ជាតិចិន បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ នាំចេញ | ៧៧៤ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

### ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៩០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

***

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់សំណើរបស់រដ្ឋសភាស្តីទី នៃព្រះរាជាណាចក្រកម្ពុជា

### ត្រាស់បង្គាប់

មាត្រា ១ .- តែងតាំងឯកឧត្តម ០៣រូប ជាទីប្រឹក្សាសម្តេច ហេង សំរិន អនុប្រធានទី១ រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា :

១-ឯកឧត្តម អ៊ុក សុគន្ធ ជាទីប្រឹក្សា ទទួលបន្ទុកកិច្ចការច្បាប់ មានឋានៈស្មើអនុរដ្ឋលេខាធិការ

២-ឯកឧត្តម ខូយ ឃុនហួរ ជាទីប្រឹក្សា ទទួលបន្ទុកសង្គមកិច្ច និង អភិវឌ្ឍន៍ជនបទ មានឋានៈស្មើអនុរដ្ឋលេខាធិការ

៣-ឯកឧត្តម ឆាំម គុសល ជាទីប្រឹក្សា ទទួលបន្ទុកទំនាក់ទំនងអន្តរជាតិ មានឋានៈស្មើ អគ្គនាយក

មាត្រា ២ .- អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា និងសាមីជនត្រូវទទួលអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី២៤ ខែ មេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

***

# ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៩១

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣

-បានទ្រង់យល់ ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់លិខិត លេខ ១៧០/រស ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីលទ្ធផលនៃការបោះឆ្នោតសំដែងការទុកចិត្តរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ។

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម សុខ ស៊ីផាន់ណា ជារដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម ជំនួសឯកឧត្តម ម៉ែន ស៊ីម៉ន ដែលត្រូវបានផ្លាស់ចេញ អោយទៅបំពេញភារកិច្ចថ្មី ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី២៩ ខែ មេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# ព្រះរាជក្រឹត្យ នស/រកត/០៤៩៩/៩២

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍ និករោត្តម

## ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

* * *-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង សមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២ / នស / ៩៤ / ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់តាមសំណើរបស់នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩ ។

## ត្រាស់បង្គាប់

**មាត្រា ១ .-** តែងតាំងឯកឧត្តម **ជុំ ភារណាល់** ជាទីប្រឹក្សាផ្ទាល់របស់សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

**មាត្រា ២ .-** បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ .-** នាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៤ .-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅថ្ងៃទី២៩ ខែ មេសា ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

**នរោត្តម សីហនុ**

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

## អនុក្រឹត្យ លេខ ៣៥ អនក្រ.បក

## ស្តីពីការរៀបចំ និងការ

## ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៨ / ៩០ ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពគ្រប់គ្រង - ដឹកនាំ នៃអាជ្ញាធរប្រេងកាត ជាតិកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ ជស / រកត / ០៣៩៦ / ១០ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រុមហ៊ុនទទួលខុសត្រូវ មានកំណត់មួយរបស់រដ្ឋមានឈ្មោះថាអគ្គិសនីកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ២០ / អនក្រ / បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី នាសម័យប្រជុំពេញអង្គ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៩

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

មាត្រា ១ .-អនុក្រឹត្យនេះ រៀបចំបណ្តាអង្គភាព នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង កំណត់បេសកកម្ម របស់ ក្រសួង និងមុខការនៃបណ្តាអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និង នាយកដ្ឋាននានា ។

## ជំពូកទី ២
## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា ២ .-** ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ត្រូវបានរាជរដ្ឋាភិបាលប្រគល់បេសកកម្មអោយដឹកនាំ និង គ្រប់គ្រងលើវិស័យ ឧស្សាហកម្ម រ៉ែ និង ថាមពល ទូទាំងព្រះរាជាណាចក្រកម្ពុជា លើកលែងតែវិស័យព្រេងកាត និងឧស្ម័ន ។

**មាត្រា ៣ .-** ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល មានមុខងារ និង ភារកិច្ច ដូចតទៅ :

- រៀបចំ និង អនុវត្តនយោបាយឧស្សាហកម្ម របស់រាជរដ្ឋាភិបាល ។
- គ្រប់គ្រង និង ផ្សព្វផ្សាយ បច្ចេកវិជ្ជា និងស្តង់ដា ដែលពាក់ព័ន្ធ នឹងសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- រៀបចំ និង អនុវត្តនយោបាយជាតិលើវិស័យធនធានរ៉ែ ក្នុងការសិក្សាស្រាវជ្រាវរុករក អភិវឌ្ឍន៍ការជីកយក ប្រត្តិកម្ម ការបន្សុទ្ធ និង អាជីវកម្ម ។
- គ្រប់គ្រង អនុវត្តការងារសិក្សាស្រាវជ្រាវ ផ្សព្វផ្សាយ ទិន្នន័យ ភូគព្ភសាស្ត្រ លើកលែងតែអ្វីដែលទាក់ទងនឹងព្រេងកាត និង ឧស្ម័ន ។
- រៀបចំ និង អនុវត្តនយោបាយជាតិ លើវិស័យថាមពល រៀបចំផែនការ គោលការណ៍ ច្បាប់ និង សហប្រតិបត្តិការ ជាមួយស្ថាប័ននានា និង ជាមួយបរទេស សំដៅអភិវឌ្ឍន៍លើវិស័យថាមពល ។
- សិក្សាស្រាវជ្រាវ ប្រព័ន្ធផ្គត់ផ្គង់ ចែកចាយ ស្ថានីយ៍អគ្គិសនី និង វាយតំលៃសក្តានុពល វារីអគ្គិសនី ដើម្បីរៀបចំអនុវត្ត តំរោងប្រព័ន្ធ អគ្គិសនី ណាដែលការផលិតថាមពលអគ្គិសនី ជាគោលបំណងចំបង ។
- រៀបចំ និង អនុវត្តនយោបាយ ផ្គត់ផ្គង់ទឹកស្អាតដល់ទីក្រុង និងទីប្រជុំជន ។
- គ្រប់គ្រង ផ្សព្វផ្សាយ ការងារមាត្រាសាស្ត្រ ។
- ចូលរួមអនុវត្តការងារពាក់ព័ន្ធ និងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង ។

**មាត្រា ៤ .-** ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល មានរចនាសម្ព័ន្ធដូចតទៅ :

ក- ថ្នាក់កណ្តាល

១- អគ្គាធិការដ្ឋាន

២- អគ្គនាយកដ្ឋាន ឧស្សាហកម្ម រួមមាននាយកដ្ឋាន ៥ :

- នាយកដ្ឋាន កិច្ចការឧស្សាហកម្ម
- នាយកដ្ឋាន ឧស្សាហកម្ម តូច - សិប្បកម្ម
- នាយកដ្ឋាន បច្ចេកទេស ឧស្សាហកម្ម
- នាយកដ្ឋាន មាត្រាសាស្ត្រ

- នាយកដ្ឋាន ទឹកស្អាត

៣- អគ្គនាយកដ្ឋាន ធនធានរ៉ែ រួមមាននាយកដ្ឋាន ៣ :

- នាយកដ្ឋាន ធនធានរ៉ែ
- នាយកដ្ឋាន ភូគព្ភសាស្ត្រ
- នាយកដ្ឋាន អភិវឌ្ឍន៍ ធនធានរ៉ែ

៤- អគ្គនាយកដ្ឋាន ថាមពល រួមមាននាយកដ្ឋាន ៣ :

- នាយកដ្ឋាន បច្ចេកទេសថាមពល
- នាយកដ្ឋាន អភិវឌ្ឍន៍ថាមពល
- នាយកដ្ឋាន វារីអគ្គិសនី

៥-នាយកដ្ឋាន រដ្ឋបាល

៦-នាយកដ្ឋាន បុគ្គលិក

៧-នាយកដ្ឋាន គណនេយ្យ និងហិរញ្ញវត្ថុ

៨-នាយកដ្ឋាន នីតិកម្ម

៩-ខុទ្ទកាល័យ

**ខ-អង្គភាពមូលដ្ឋាន**

-មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល និង សាខាសមត្ថកិច្ចជំនាញ ខេត្ត-ក្រុង

**គ-ក្រុមហ៊ុនរដ្ឋ ស្ថិតនៅក្រោមច្បាប់ ស្តីពីលក្ខន្តិកៈ សហគ្រាសសាធារណៈ**

-អគ្គិសនីកម្ពុជា

**ឃ-ក្រុមហ៊ុន និង អង្គភាព ដែលកំពុងអនុវត្តតាមអនុក្រឹត្យលេខ ៤១ អនក្រ.បក**

-ក្រុមហ៊ុនសំភារៈដឹកជញ្ជូន

-រោងចក្រ យន្តសាស្ត្រទី១

-រោងពុម្ព ឧស្សាហកម្ម

## ជំពូកទី ៣

## អគ្គាធិការដ្ឋាន

**មាត្រា ៥ .-** អគ្គាធិការដ្ឋាន ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ទទួលបន្ទុក :

- ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- ធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រី ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយ និង ពីមធ្យោបាយកែលំអរការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។
- ប្រតិបត្តិភារកិច្ច ដែលរដ្ឋមន្ត្រីបានប្រគល់ ។

អគ្គាធិការដ្ឋានដឹកនាំ ហើយអគ្គាធិការមួយរូប និងអមដោយអគ្គាធិការរងជាជំនួយការ តាមការចាំបាច់ ។

## ជំពូកទី ៣

## អគ្គនាយកដ្ឋានឧស្សាហកម្ម

**មាត្រា ៦ .-** អគ្គនាយកដ្ឋាន ឧស្សាហកម្ម ទទួលបន្ទុក :

- រៀបចំនយោបាយ យុទ្ធសាស្ត្រ ទិសដៅ និង ផែនការរួមរបស់ក្រសួង

- រៀបចំ គ្រប់គ្រង ផ្សព្វផ្សាយ និង អភិវឌ្ឍន៍ ឧស្សាហកម្ម សិប្បកម្ម ។
- រៀបចំ គ្រប់គ្រង និង ផ្សព្វផ្សាយ ការងារ ស្តង់ដា ។
- រៀបចំ គ្រប់គ្រង និង អភិវឌ្ឍន៍ផលិតកម្មទឹកស្អាត ។
- រៀបចំ គ្រប់គ្រង និង ផ្សព្វផ្សាយ ការងារមាត្រាសាស្ត្រ ។

អគ្គនាយកដ្ឋាន ឧស្សាហកម្ម ដឹកនាំដោយអគ្គនាយកមួយរូប និង អមដោយអគ្គនាយករងជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋាន ឧស្សាហកម្ម មាននាយកដ្ឋានចំណុះ ៥ :

**មាត្រា ៧ .-** នាយកដ្ឋាន កិច្ចការឧស្សាហកម្ម ទទួលបន្ទុក :

- រៀបចំផែនការរយៈពេលខ្លី មធ្យម វែង និងផែនការមេ ស្របតាមនយោបាយ របស់រាជរដ្ឋាភិបាល និងអនុវត្តកម្មវិធី អភិវឌ្ឍន៍វិស័យឧស្សាហកម្ម ។
- ជំរុញលើកទឹកចិត្ត តំរង់ទិស និងគាំទ្រ ឧស្សាហកម្មធំ និងមធ្យម និងអនុវត្តច្បាប់គោលនយោបាយនានា នៃវិស័យឧស្សាហកម្ម ។
- រៀបចំច្បាប់ បទបញ្ញា លិខិតបទដ្ឋាននានា រួមទាំងផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ ដែលពាក់ព័ន្ធនឹង ការងារឧស្សាហកម្ម ។
- សហប្រតិបត្តិការជាមួយអាស៊ាន បណ្តាប្រទេស ស្ថាប័ន អង្គការជាតិ និងអន្តរជាតិនានា ដើម្បីជំរុញ អភិវឌ្ឍន៍ឧស្សាហកម្ម ។
- ពិនិត្យ វាយតំលៃ និងលើកយោបល់លើគំរោងវិនិយោគ ឯកជនដោយផ្ទាល់ ឬ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- លើកនិងសរសេររួមគំរោងវិនិយោគសាធារណៈ និងពិនិត្យតាមដានការអនុវត្តន៍គំរោង ។
- សិក្សា វាយតំលៃ កំណត់ទីតាំងសំរាប់ការងាររៀបចំ គំរោងបង្កើត តំបន់ឧស្សាហកម្ម ។
- រៀបចំ ប្រកាសអនុញ្ញាតអោយរោងចក្រធុនធំ និង មធ្យមដំណើរការ ។
- វាយតំលៃលើយន្តប្រភេទ និង បរិមាណវត្ថុធាតុដើមប្រើប្រាស់របស់រោងចក្រតាមបទដ្ឋាន បច្ចេកទេស និងតាមដានការប្រើប្រាស់ ។
- រៀបចំ បញ្ជីផលិតផលឧស្សាហកម្ម ។
- ផ្តល់លិខិតបញ្ជាក់នានា ដែលពាក់ព័ន្ធដល់ផលិតកម្មរបស់រោងចក្រ និង សហគ្រាស ។
- ប្រមូលផ្តុំទិន្នន័យ និង វិភាគវាយតំលៃលទ្ធផលអនុវត្តឧស្សាហកម្មធំ និងមធ្យមដែលរាប់ ៥ ផ្នែកពី :

១- ផ្នែក ស្បៀង ម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់

២- ផ្នែក វាយនភ័ណ្ឌ សំលៀកបំពាក់ និង ផលិតផលអំពីស្បែក

៣- ផ្នែក ផលិតផល អំពីឈើ អនុផលព្រៃឈើ

៤- ផ្នែក ផលិតផលក្រដាស

៥- ផ្នែក គីមី ផលិតផលពីកៅស៊ូ ប្លាស្ទិក

៦- ផ្នែក ផលិតផលពីដី មិនមែនជាលោហៈ

៧- ផ្នែក ឧស្សាហកម្ម លោហៈមូលដ្ឋាន

៨- ផ្នែក ឧស្សាហកម្ម កែច្នៃលោហៈ

៩- ផ្នែក ឧស្សាហកម្ម ផ្សេងៗ

- ពិនិត្យដោះស្រាយ សកម្មភាពមិនប្រក្រតី របស់មូលដ្ឋានឧស្សាហកម្ម ធំ មធ្យម ដោយអនុលោមទៅតាមច្បាប់លិខិតបទដ្ឋាននានា ។
- សហការជាមួយក្រសួងទទួលបន្ទុកវិស័យការងារ ដើម្បីអនុវត្តច្បាប់ ស្តីពីការងារ ។

**មាត្រា ៨ .-** នាយកដ្ឋានឧស្សាហកម្មតូច សិប្បកម្ម ទទួលបន្ទុក :

- រៀបចំផែនការរយៈពេលខ្លី មធ្យម វែង និងផែនការមេ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល និង អនុវត្តកម្មវិធី អភិវឌ្ឍន៍វិស័យឧស្សាហកម្មតូច សិប្បកម្ម ។
- ជំរុញលើកទឹកចិត្ត តំរង់ទិស និងគាំទ្រ ឧស្សាហកម្មតូច សិប្បកម្ម និង អនុវត្តច្បាប់គោលនយោបាយនានា នៃវិស័យឧស្សាហកម្មតូច សិប្បកម្ម ។
- រៀបចំច្បាប់ បទបញ្ញា លិខិតបទដ្ឋាននានា រួមទាំងផ្នែកហិរញ្ញវត្ថុ និងសារពើពន្ធ ដែលពាក់ព័ន្ធនឹង ការងារឧស្សាហកម្មតូច សិប្បកម្ម ។
- សហប្រតិបត្តិការជាមួយបណ្តាប្រទេស ស្ថាប័ន អង្គការជាតិ និងអន្តរជាតិនានា ដើម្បីជំរុញអភិវឌ្ឍន៍ឧស្សាហកម្មតូច សិប្បកម្ម ។
- ពិនិត្យ វាយតំលៃ និងអនុម័តលើគំរោងវិនិយោគ ដែលដាក់ដោយផ្ទាល់ ឬដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។
- លើក និង ស៊ើបសួរលំអៀងវិនិយោគសកម្មភាពនោះ និងពិនិត្យតាមដានការអនុវត្តន៍គំរោង ។
- រៀបចំ ប្រកាសអនុញ្ញាតលើមូលដ្ឋានឧស្សាហកម្មតូច សិប្បកម្ម ជំនួសវិញ ។
- វាយតំលៃអេស៊ីយចាប្រភេទ និង ពណ៌រហោថ្នាក់ជីវភាពវត្ថុធាតុដើមប្រើប្រាស់របស់ឧស្សាហកម្មតូច សិប្បកម្ម តាមបទដ្ឋាន បច្ចេកទេស និងតាមដានការប្រើប្រាស់ ។
- រៀបចំ បញ្ជីផលិតផលឧស្សាហកម្មតូច សិប្បកម្ម ។
- ផ្តល់លិខិតបញ្ជាក់នានា ដែលពាក់ព័ន្ធដល់ផលិតកម្មរបស់ឧស្សាហកម្មតូច សិប្បកម្ម ។
- ប្រមូលស្ថិតិទិន្នន័យ និង វិភាគវាយតំលៃលទ្ធផលអនុវត្តឧស្សាហកម្មតូច សិប្បកម្មដែលចែកជា ១០ផ្នែក គឺ :

  ១- ផ្នែក គ្រឿង ម្ហូបអាហារ ភេសជ្ជៈ និង ថ្នាំជក់

  ២- ផ្នែក វាយនភ័ណ្ឌ សំលៀកបំពាក់ និង ផលិតផលពីស្បែក

  ៣- ផ្នែក ផលិតផល អំពីឈើ អនុផលព្រៃឈើ

  ៤- ផ្នែក ផលិតផលក្រដាស

  ៥- ផ្នែក គីមី ផលិតផលពីកៅស៊ូ ផ្លាស្ទិក

  ៦- ផ្នែក ផលិតផលពីដី មិនមែនជាលោហៈ

៧- ផ្នែក ឧស្សាហកម្ម កែច្នៃកៅស៊ូ
៨- ផ្នែក ឧស្សាហកម្ម កែច្នៃផលិតផលកសិកម្ម
៩- ផ្នែក ឧស្សាហកម្ម ផ្សេងៗ
១០- សិប្បកម្មប្រពៃណី

**មាត្រា ៩ .-** នាយកដ្ឋានបច្ចេកទេស ឧស្សាហកម្ម ទទួលបន្ទុក :

-អនុវត្តគោលនយោបាយលើកស្ទួយការអភិវឌ្ឍន៍វិទ្យាសាស្ត្របច្ចេកទេសរបស់រដ្ឋនិងគ្រប់គ្រងការងារផ្ទេរបច្ចេកវិជ្ជា នៅតាមរោងចក្រសហគ្រាស ។
-ត្រួតពិនិត្យសកម្មភាព ឧស្សាហកម្ម សិប្បកម្ម កុំអោយមានការខានដល់ការរស់នៅរបស់ប្រជាជន និងប៉ះពាល់ដល់បរិស្ថាន ដោយរួមសហការជាមួយក្រសួងបរិស្ថាន ។
- គ្រប់គ្រង និង ត្រួតពិនិត្យ គុណភាពផលិតផលឧស្សាហកម្ម សិប្បកម្ម ក្នុងទីតាំងរោងចក្រ និងសិប្បកម្ម ។
- គ្រប់គ្រង ការងារវិញ្ញាបនប័ត្របញ្ជាក់ផលិតកម្ម ។
- គ្រប់គ្រងមន្ទីរពិសោធន៍ឧស្សាហកម្ម ។
- គ្រប់គ្រងការងារកម្មសិទ្ធិឧស្សាហកម្ម រួមមាន សញ្ញាសំគាល់ផលិតផល និងសេវា ប្រកាសនីយប័ត្រតក្កកម្ម គំនូរ និង រាងគំរូឧស្សាហកម្ម ។
- សហការ គ្រប់គ្រង និងរៀបចំ ផ្នែកបច្ចេកទេសទូទៅ លើរោងការងារសំណង់ឧស្សាហកម្ម សិប្បកម្ម ដើម្បីធានាសុវត្ថិភាពឧស្សាហកម្ម ។
- គ្រប់គ្រងការងារស្តង់ដារូបនីយកម្ម ក្នុងផ្នែកឧស្សាហកម្ម និងសេវាកម្ម ។
- គ្រប់គ្រងការងារគ្រឿងចក្រ គ្រឿងម៉ាស៊ីន សុវត្ថិភាពបច្ចេកទេស និងពិនិត្យរោងលើការនាំចូល ការប្រើប្រាស់គ្រឿងចក្រ គ្រឿងម៉ាស៊ីន តាមដានការប្រើប្រាស់ ដែលរាប់បញ្ចូលវិស័យឧស្សាហកម្ម ។
- គ្រប់គ្រង បញ្ញត្តិ នៃសញ្ញាធូតក្នុងវិស័យឧស្សាហកម្ម ។
- បណ្តុះបណ្តាលអំពីការគ្រប់គ្រង ក្នុងវិស័យវិទ្យាសាស្ត្របច្ចេកទេស ឧស្សាហកម្ម ។
- គ្រប់គ្រងការងារស្តង់ដារូបនីយកម្ម ក្នុងផ្នែកឧស្សាហកម្ម និងសេវាកម្ម ។

**មាត្រា ១០ .-** នាយកដ្ឋាន មាត្រាសាស្ត្រ ទទួលបន្ទុក :

- រៀបចំគ្រប់គ្រង អនុវត្តនយោបាយជាតិផ្នែកមាត្រាសាស្ត្រ និងតាក់តែងឯកសារ បទ... ការងារដែលទាក់ទងនឹងមាត្រាសាស្ត្រ មានជាអាទិ ការផ្គួសផ្គុំ ការផលិត ការប្រើប្រាស់ និងការនាំចូល នាំចេញ ឧបករណ៍មាត្រាសាស្ត្រ ។
-ត្រួតពិនិត្យតាមដាន ក្នុងការអនុវត្តន៍ខ្នាតគំរូ ដើម្បីធានាអោយមានប្រសិទ្ធភាពនិងសុក្រឹតភាព ។
-សំរបសំរួល សហការជាមួយស្ថាប័នសមត្ថកិច្ច ក្នុងការទប់ស្កាត់បទល្មើស ក្នុងការប្រើប្រាស់ឧបករណ៍ មាត្រាសាស្ត្រ ។
- ផ្សព្វផ្សាយលើកកំពស់ បច្ចេកវិជ្ជា មាត្រាសាស្ត្រជាតិ និង អន្តរជាតិ ។

- រៀបចំគ្រប់គ្រង មន្ទីរពិសោធន៍អាកាសធាតុ និងកន្លែងជួសជុលឧបករណ៍ផ្សេងៗ ដែលពាក់ព័ន្ធដល់អាកាសធាតុ ។
- សហប្រតិបត្តិការជាតិ និងអន្តរជាតិក្នុងការរៀបចំ ជំរុញវិស័យអាកាសធាតុ ។

**មាត្រា ១១ .-** នាយកដ្ឋាន ទឹកស្អាត ទទួលបន្ទុក :

- រៀបចំគ្រប់គ្រង ត្រួតពិនិត្យការធ្វើផលិតកម្ម-អាជីវកម្ម ទឹកស្អាតនៅទីក្រុង និងទីប្រជុំជន ទូទាំងប្រទេស ។
- សិក្សាបច្ចេកទេស លើអាងោមាត្រវិធី និងលើការធ្វើអាជីវកម្ម បណ្តាញចែកចាយរបស់ជាតិ ។
- ប្រមូលពត៌មាន និងធ្វើបញ្ជីសារពើភ័ណ្ឌ ស្ថានីយ៍ផលិតទឹកស្អាត ។
- រៀបចំគោលនយោបាយច្បាប់ បទបញ្ញា ស្តីពីការគ្រប់គ្រង និងការប្រើប្រាស់ទឹកស្អាត ។
- រៀបចំគោលនយោបាយ បទបញ្ញា ស្តីពីការកំណត់ថ្លៃទឹកស្អាត ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង ។
- រៀបចំមន្ទីរពិសោធន៍ ទឹកស្អាត ត្រួតពិនិត្យគុណភាពទឹក ត្រូវតាមស្តង់ដាជាតិ ។
- រៀបចំប្រកាសអនុញ្ញាតអោយធ្វើផលិតកម្ម អាជីវកម្មទឹកស្អាត ។
- សំរបសំរួល ទំនាក់ទំនងជាមួយនឹងស្ថាប័ននានាដែលពាក់ព័ន្ធដើម្បីដោះស្រាយការងារ ទឹកស្អាត ។
- សហប្រតិបត្តិការអន្តរជាតិ ដើម្បីអភិវឌ្ឍន៍វិស័យទឹកស្អាត ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ ។

## ជំពូកទី ៥

## អគ្គនាយកដ្ឋាន ធនធានរ៉ែ

**មាត្រា ១២ .-** អគ្គនាយកដ្ឋានធនធានរ៉ែ ទទួលបន្ទុក :

- រៀបចំ គ្រប់គ្រង ភូគព្ភសាស្ត្រ និង អភិវឌ្ឍន៍ ធនធានរ៉ែ ។
- ផ្សព្វផ្សាយលើកកំពស់កិច្ចការ ភូគព្ភសាស្ត្រ និង ធនធានរ៉ែ ។
- លើកទឹកចិត្តដល់ការសិក្សាស្រាវជ្រាវ រុករក ការវាយតំលៃសក្តានុពល និងការធ្វើអាជីវកម្ម ធនធានរ៉ែ ត្រួសខ្សាច់ និងថ្មសំភារៈសំណង់ ។
- រៀបចំ និង លើកកំពស់កិច្ចការស្រាវជ្រាវ ភូគព្ភសាស្ត្រ ។

-អគ្គនាយកដ្ឋាន ធនធានរ៉ែ ដឹកនាំដោយអគ្គនាយកមួយរូប និង អមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។

-អគ្គនាយកដ្ឋានធនធានរ៉ែ មាននាយកដ្ឋានចំណុះ ចំនួន ៣ ។

**មាត្រា ១៣ .-** នាយកដ្ឋានធនធានរ៉ែ ទទួលបន្ទុក :

- វិភាគវិធីសាស្ត្រ និងវិធានការ ដើម្បីអនុវត្ត គ្រប់គ្រងការសិក្សាស្រាវជ្រាវ រុករកការវាយតំលៃ ការជីកយក ការធ្វើប្រព្រឹត្តកម្ម ការបន្សុទ្ធ ការរកទីផ្សារធនធានរ៉ែ ត្រួសខ្សាច់និងថ្មសំភារៈ

សំណង់ឱ្យមានប្រសិទ្ធភាព ទាំងបច្ចេកទេស សេដ្ឋកិច្ច សុវត្ថិភាពពលកម្ម និងការពារបរិស្ថាន ។

- អនុវត្តច្បាប់ អនុក្រឹត្យ បទបញ្ជា និងលិខិតបទដ្ឋាន ដែលទាក់ទងដល់ការរុករក ការវាយតម្លៃ និង ការធ្វើអាជីវកម្មធនធានរ៉ែ គ្រួសខ្សាច់ និងថ្មសំភារៈសំណង់ទូទាំងប្រទេស ។
- សិក្សាស្រាវជ្រាវ រុករក វាយតម្លៃ ដើម្បីកំណត់បរិមាណ គុណភាព ធនធានរ៉ែ គ្រួស ខ្សាច់ និងថ្មសំភារៈ សំណង់ ធ្វើបញ្ជីសារពើភ័ណ្ឌ ។
- សិក្សា និងផ្តល់មតិ លើគំរោងវិនិយោគទុនស្វែងរុករក និងអាជីវកម្មធនធានរ៉ែ គ្រួសខ្សាច់ និងថ្មសំភារៈសំណង់ ។
- គ្រប់គ្រង ណែនាំ ពិនិត្យ និងតាមដានការអនុវត្តន៍ច្បាប់ អនុក្រឹត្យ បទបញ្ជា លិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងធនធានរ៉ែ ។

មាត្រា ១៤ .- នាយកដ្ឋានភូគព្ភសាស្ត្រ ទទួលបន្ទុក :

- អនុវត្តច្បាប់ អនុក្រឹត្យ បទបញ្ជា និង លិខិតបទដ្ឋាន ដែលទាក់ទងដល់ការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ ។
- ធ្វើការសិក្សា ភូគព្ភសាស្ត្រ រូបភូគព្ភសាស្ត្រ និង គីមី ភូគព្ភសាស្ត្រ ។
- ធ្វើការសិក្សា វាយតម្លៃ រ៉ែ និងគូសផែនទី ។
- ប្រមូល រក្សាទុក គ្រប់គ្រង ប្រើប្រាស់ ផ្លាស់ប្តូរ និងលក់នូវទិន្នន័យ និងសៀវភៅភូគព្ភសាស្ត្រនានា ដែលបង្កើតបានជាឯកសារ ពត៌មាន លើកលែងអ្វីដែលទាក់ទងនឹងវិស័យប្រេងកាត និង ឧស្ម័ន ។
- ធ្វើសំយោគទិន្នន័យភូគព្ភសាស្ត្រ តាមតំបន់នានានៃប្រទេសកម្ពុជា និងតាមសក្តានុពល ធនធាន រ៉ែ សមស្របទៅតាមផលប្រយោជន៍ផ្នែកភូគព្ភសាស្ត្រ ឬ ផលប្រយោជន៍ ផ្នែកទេសចរណ៍ និងផ្នែករៀបចំក្រុង និងសំណង់ ។
- ផ្សព្វផ្សាយ លើកកំពស់ការសិក្សាស្រាវជ្រាវ ភូគព្ភសាស្ត្រ និងគងក្រុងផែនទីដែលទាក់ទងនឹងវិស័យភូគព្ភសាស្ត្រ ធនធានរ៉ែ ។
- ប្រមូលរាល់ចំណេះដឹង ផ្នែកភូគព្ភសាស្ត្រ មកអនុវត្តក្នុងការរៀបចំប្រើប្រាស់ដីធ្លី ការពារបរិស្ថាន និងទប់ស្កាត់គ្រោះថ្នាក់ធម្មជាតិ ។

មាត្រា ១៥ .- នាយកដ្ឋានអភិវឌ្ឍន៍ធនធានរ៉ែ ទទួលបន្ទុក :

- រៀបចំនយោបាយ អភិវឌ្ឍន៍វិស័យធនធានរ៉ែ និងភូគព្ភសាស្ត្រ ទូទាំងប្រទេស ។
- រៀបចំច្បាប់អនុក្រឹត្យ បទបញ្ជា និងលិខិតបទដ្ឋាន និងកិច្ចព្រមព្រៀងវិនិយោគទុនដែលទាក់ទងដល់

  ការសិក្សា ស្រាវជ្រាវភូគព្ភសាស្ត្រ ការរុករក ការវាយតម្លៃ និងការធ្វើអាជីវកម្មធនធានរ៉ែ គ្រួសខ្សាច់ និងថ្មសំភារៈសំណង់ទូទាំងប្រទេស ។

- បើកចំរោង និង អនុវត្តកិច្ចសហប្រតិបត្តិការ ជាមួយបណ្តាក្រសួងនានា និងសហគមន៍អន្តរជាតិ ដើម្បីប្រមូល និងធ្វើវិភាគលើទិន្នន័យធនធានរ៉ែ ត្បូងរឡាក់ និងថ្មសំភារៈសំណង់ទាំងក្នុង និងក្រៅប្រទេស និងរៀបចំជាមជ្ឈមណ្ឌលទិន្នន័យធនធានរ៉ែ ត្បូងរឡាក់ និងថ្មសំភារៈសំណង់ ។
- សហការជាមួយនាយកដ្ឋានពាក់ព័ន្ធ ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលធនធានមនុស្ស លើជំនាញដែលចាំបាច់បំរើអោយការងារភូគព្ភសាស្ត្រ និង ធនធានរ៉ែ ។

## ជំពូកទី ៦

## អគ្គនាយកដ្ឋាន ថាមពល

មាត្រា ១៦ .- អគ្គនាយកដ្ឋានថាមពល ទទួលបន្ទុក :

- រៀបចំគោលការណ៍ គោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋាន ស្តីពីការប្រើប្រាស់ និងការគ្រប់គ្រង វិស័យថាមពលអគ្គិសនី និងថាមពលផ្សេងៗទៀត ។
- សិក្សាស្រាវជ្រាវ រៀបចំ និងអនុវត្តផែនការ អភិវឌ្ឍវិស័យថាមពល ដោយធានានិងការពារនូវផលប្រយោជន៍របស់សង្គម ។
- ផ្លាស់ប្តូរ បច្ចេកវិជ្ជាវិទ្យាសាស្ត្រ ព្រមទាំងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ ជាតិ និងអន្តរជាតិ លើវិស័យថាមពល អេឡិចត្រូនិក និងបរមាណូ ។
- ត្រួតពិនិត្យ ណែនាំអោយបណ្តាក្រុមហ៊ុន អង្គភាពអគ្គិសនីក្នុងក្របខ័ណ្ឌទូទាំងប្រទេសអនុវត្តត្រឹមត្រូវតាមច្បាប់ អនុក្រឹត្យ សេចក្តីសំរេច សារាចរ សេចក្តីណែនាំ ស្តីពីការប្រើប្រាស់ និងផ្គត់ផ្គង់ថាមពលអគ្គិសនីគ្រប់ប្រភេទ ។
- រៀបចំគ្រប់គ្រង បទដ្ឋានស្តង់ដាផ្នែកថាមពល និងរៀបចំគោលការណ៍អគ្គិសនីភាវូបនីយកម្មទីរួមខេត្ត និងជនបទ ។
- ផ្សព្វផ្សាយអំពី ការប្រើប្រាស់ថាមពលគ្រប់ប្រភេទដោយសន្សំសំចៃ និងមានប្រសិទ្ធភាពខ្ពស់ធានាបានជាអតិបរមា ដល់ការថែរក្សា និងការពារបរិស្ថាន ។
- ចូលរួមអនុវត្តការងារពាក់ព័ន្ធនឹងអាងទន្លេមេគង្គ ស្របតាមភារកិច្ចរបស់ក្រសួង ។
- រៀបចំបណ្តុះបណ្តាលជំនាញបច្ចេកទេស និងគ្រប់គ្រងសេដ្ឋកិច្ចផ្នែកថាមពល ។

អគ្គនាយកដ្ឋានថាមពល ដឹកនាំដោយអគ្គនាយកមួយរូប និងអមដោយអគ្គនាយករងជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានថាមពល មាននាយកដ្ឋានចំណុះ ៣ ។

មាត្រា ១៧ .- នាយកដ្ឋាន បច្ចេកទេស ថាមពល ទទួលបន្ទុក :

- វិភាគ និងវាយតំលៃ លើទិន្នន័យ ផ្គត់ផ្គង់ តំរូវការប្រើប្រាស់ថាមពល ខេត្ត-ក្រុង ទូទាំងប្រទេស ។
- សិក្សាស្រាវជ្រាវ ប្រព័ន្ធផ្គត់ផ្គង់ និងចែកចាយថាមពល នៅតាមបណ្តាខេត្ត-ក្រុង ។

- រៀបចំ គ្រប់គ្រង បទដ្ឋានស្តង់ដា វិស័យថាមពល ។
- ផ្សព្វផ្សាយពត៌មាន ស្តីពីប្រភពថាមពល ដែលមាននៅក្នុងប្រទេស ។
- ផ្សព្វផ្សាយអំពីការប្រើប្រាស់ថាមពលគ្រប់ប្រភេទ ដោយមានប្រសិទ្ធភាពខ្ពស់ ក្នុងលក្ខណៈសន្សំសំចៃ ។
- ធានាអោយបានជាអតិបរមា ដល់ការថែរក្សា ការពារបរិស្ថាន ។
- គ្រប់គ្រងការចុះបញ្ជី និងការរៀបចំប្រកាសអនុញ្ញាតក្នុងការធ្វើអាជីវកម្ម សេវាកម្ម អគ្គិសនី ។

មាត្រា ១៨ .- នាយកដ្ឋាន អភិវឌ្ឍន៍ ថាមពល ទទួលបន្ទុក :

- សិក្សារៀបចំគោលនយោបាយ និងយុទ្ធសាស្ត្រ សំរាប់អភិវឌ្ឍន៍វិស័យថាមពល ដោយសហប្រតិបត្តិការ ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងសហប្រតិបត្តិការអន្តរជាតិ ។
- ជំរុញការអភិវឌ្ឍន៍ និងអនុវត្តបច្ចេកវិជ្ជាដែលពាក់ព័ន្ធ នឹងថាមពលអគ្គិសនី អេឡិចត្រូនិក បរមាណូ ។
- រៀបចំគំរោងផែនការ ផ្នែកអគ្គិសនី និងថាមពលផ្សេងទៀតសំរាប់រយៈពេលខ្លី-មធ្យម-វែង ។
- រៀបចំ លិខិតបទដ្ឋានផ្សេងៗ ពាក់ព័ន្ធនឹងវិស័យថាមពលអគ្គិសនីនិងថាមពលផ្សេងៗទៀត ។
- ស្រាវជ្រាវ និងកំណត់សក្តានុពល ធនធានថាមពលទាំងអស់ ដើម្បីកសាងផែនការបំរើដល់ការអភិវឌ្ឍន៍វិស័យថាមពលនៅកម្ពុជា ។
- គ្រប់គ្រង អគ្គិសនីភាវូបនីយកម្ម ទីរួមខេត្ត និង ជនបទ ។
- រាយការណ៍បូកសរុប រៀបចំផែនការ បណ្តុះបណ្តាលធនធានមនុស្សសំរាប់វិស័យថាមពល

មាត្រា ១៩ .- នាយកដ្ឋាន វារីអគ្គិសនី ទទួលបន្ទុក :

- រៀបចំនិងអនុវត្តនយោបាយ ថាមពលជាតិ ដែលទាក់ទងនឹងវិស័យវារីអគ្គិសនី ។
- ប្រមូល វិភាគ និង រក្សាទុក ប្រើប្រាស់នូវរាល់ទិន្នន័យសំរាប់ការសិក្សា និង ការអភិវឌ្ឍន៍វិស័យវារីអគ្គិសនី ។
- ជ្រើសរើសទីតាំង ព្រមទាំងគំរោងអាទិភាព ។
- រៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍វារីអគ្គិសនី ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ។
- សិក្សា រៀបចំ អនុវត្ត និងត្រួតពិនិត្យគំរោងកសាង ស្ថានីយ៍វារីអគ្គិសនី ។

## ជំពូកទី ៧

## ការងាររដ្ឋបាល បុគ្គលិក ហិរញ្ញវត្ថុ និង នីតិកម្ម

មាត្រា ២០ .- នាយកដ្ឋាន រដ្ឋបាល ទទួលបន្ទុក :

- សំរបសំរួល សកម្មភាពគ្រប់ផ្នែក របស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមឱវាទ និងអង្គភាពដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស ។
- គ្រប់គ្រង និងតម្កល់ឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង ។

- ធានាប្រសិទ្ធភាព សុវត្ថិភាព រដ្ឋបាល និងគ្រប់គ្រងការងារសវនកម្មរបស់ក្រសួង ។
- សរុប និងធ្វើរបាយការណ៍ការងារ និងកម្មភាពផ្សេងៗរបស់ក្រសួង ។
- គ្រប់គ្រងឃ្លាំងដ្ឋាន និងយានយន្ត របស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធី ចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ ។
- ទទួល និងបែងចែកបរិក្ខារ ជូនដល់បណ្តាអង្គភាព ខេត្ត-ក្រុង នានា ។

មាត្រា ២១ .- នាយកដ្ឋាន បុគ្គលិក ទទួលបន្ទុក :

- គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ មិនមែនមន្ត្រីរាជការរបស់ក្រសួង ដោយទំនាក់ទំនង នឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ។
- រៀបចំរាល់លិខិតរដ្ឋបាល សំរាប់ការគ្រប់គ្រងអាជីព ។
- ធ្វើកម្មវិធីកំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង ។
- រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងព័ត៌មានប្រតិបត្តិ ។
- រៀបចំការងារ សេវាតុលាការកម្ម ប្រាក់កំរៃ និង របបឧបត្ថម្ភសន្តិសុខសង្គម ។
- វាយតំលៃតំរូវការ ក្នុងការបណ្តុះបណ្តាលបុគ្គលិក ។
- រៀបចំនយោបាយ បណ្តុះបណ្តាលដំបូង និងបន្តដោយទំនាក់ទំនងរដ្ឋលេខាធិការដ្ឋានមុខងារ សាធារណៈ និងអនុវត្តនយោបាយនោះ ។

មាត្រា ២២ .- នាយកដ្ឋាន គណនេយ្យ - ហិរញ្ញវត្ថុ ទទួលបន្ទុក :

- លើកគំរោងថវិកាក្រសួង និងតាមដានវិលើកពីការប្រតិបត្តិ ។
- ប្រមូលវត្ថុ និងសំរបស់រូបជំពូកថវិកា ។
- តាមដានរំលឹកការគ្រប់គ្រង គណនីពិសេស ។
- ប្រមូលវត្ថុ និងសំរបស់រូបរាល់ចំណាយរបស់ក្រសួង ។
- គ្រប់គ្រងបន្ទុកគណនី នូវការអនុវត្តន៍ លទ្ធកម្មសាធារណៈ ។
- ប្រមូលផ្តុំចំណូលអោយបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ ដែលបានកំណត់ ។
- ប្រមូលផ្តុំតំរូវការ ធ្វើកម្មវិធីចំណាយ គ្រប់គ្រងការរៀបចំជួសជុលសំភារៈ និងបរិក្ខាររបស់ ក្រសួង ។
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ ។
- កាន់បញ្ជីជាប្រចាំ នូវសលាកប័ត្រ និងគណនេយ្យរូបធាតុ ។
- ពត៌មានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី ។
- ត្រួតពិនិត្យបច្ចេកទេស ផែនការប្រតិបត្តិ លទ្ធកម្ម សាធារណៈ ។

មាត្រា ២៣ .- នាយកដ្ឋាន នីតិកម្ម ទទួលបន្ទុក :

- រៀបចំតាក់តែងសេចក្តីព្រាងច្បាប់ ឧស្សាហកម្ម រ៉ែ និងថាមពល ។

- កាន់កាប់បញ្ជីនិងគ្រប់គ្រងសមត្ថភាពឧស្សាហកម្មរ៉ែ និង ថាមពល ដែលមានចែងក្នុងច្បាប់ ស្ដីពីការគ្រប់គ្រងរោងចក្រ អនុក្រឹត្យ ស្ដីពីអាជ្ញាធរតំបន់ឧស្សាហកម្ម ច្បាប់ ទំងន់ រង្វាស់ រង្វាល់ ច្បាប់ ស្ដីពីការគ្រប់គ្រងធនធានរ៉ែ ច្បាប់ អគ្គិសនី ។
- ស្រាវជ្រាវ ដកស្រង់ ចងក្រង អត្ថបទច្បាប់ឧស្សាហកម្ម រ៉ែ និងថាមពល និងសន្ធិសញ្ញាវិស័យ ឧស្សាហកម្ម រ៉ែ និង ថាមពល និងគ្រប់គ្រងអត្ថបទច្បាប់ទាំងនេះ ។
- ណែនាំតាមដានការអនុវត្តន៍ច្បាប់ ឧស្សាហកម្មរ៉ែ និងថាមពល និងសន្ធិសញ្ញាវិស័យ ឧស្សាហកម្ម រ៉ែ និងថាមពល ។
- ជាអ្នកជំនួយការច្បាប់ ឧស្សាហកម្មរ៉ែ និងថាមពល សំរាប់ថ្នាក់ដឹកនាំក្រសួង និងបណ្ដាអង្គភាព ឧស្សាហកម្ម សិប្បកម្ម និង អង្គភាពក្រោមអាណាព្យាបាលបច្ចេកទេស របស់ក្រសួង ។
- ដោះស្រាយវិវាទ និង ការងារពាក់ព័ន្ធនឹងតុលាការ ។

## ជំពូកទី ៨

## ខុទ្ទកាល័យ

**មាត្រា ២៤ .-** ខុទ្ទកាល័យរដ្ឋមន្ត្រី ទទួលបេសកកម្មទាំងឡាយ ដែលកំណត់តាមបទបញ្ញត្តិ នៃអនុក្រឹត្យលេខ ២០ អនក្រ ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូកទី ៩

## អង្គភាពមូលដ្ឋាន

**មាត្រា ២៥ .-** នៅតាមខេត្ត-ក្រុង នីមួយៗ មានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល និង សាខាសមត្ថកិច្ចជំនាញខេត្ត-ក្រុង ដែលទទួលបន្ទុកអនុវត្ត និង សំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូកទី ១០

## អង្គភាពត្រួតពិនិត្យ ហិរញ្ញវត្ថុ

**មាត្រា ២៦ .-** អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ញាកំណត់ ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតស្ថាប័ន ត្រួតពិនិត្យ ហិរញ្ញវត្ថុ លើការចំណាយថវិកា ក្នុងបណ្ដាក្រសួង ។

## ជំពូកទី ១១

## អវសានបញ្ញត្តិ

**មាត្រា ២៧ .-** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង នៅថ្នាក់កណ្ដាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ និង មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្ត-ក្រុង ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រី ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ២៨** .- ភារកិច្ចទាំងឡាយណាដែលពាក់ព័ន្ធនឹងសមត្ថកិច្ច របស់ស្ថាប័នដទៃ ប្រធានស្ថាប័ន នៃស្ថាប័នដទៃទាំងនោះ និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវសហការគ្នាដើម្បីបែងចែកការងារទទួលខុសត្រូវ និងអនុវត្តការងារទាំងនោះតាមរយៈប្រកាសរួម របស់រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល និងប្រធានស្ថាប័នទាំងនោះ ។

**មាត្រា ២៩** .- បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣០** .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា ៣១** .-អនុក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ហ៊ុន សែន**

★★★

## អង្គការលេខរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល



# អនុក្រឹត្យ លេខ ៣៦ អនក្រ.បក
# ស្តីពីការគ្រប់គ្រងសំណល់រឹង

* * *

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៥ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

-បានការយល់ព្រមពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ២ ខែ មេសា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** អនុក្រឹត្យនេះ មានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេស សមស្រប និងប្រកបដោយសុវត្ថិភាព សំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវចំរុះ ។

**មាត្រា ២ .-** អនុក្រឹត្យនេះមានវិសាលភាពអនុវត្ត ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

**មាត្រា ៣ .-** និយមន័យពាក្យបច្ចេកទេសដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានបកស្រាយដូចតទៅ :

ក- "**សំណល់រឹង**" គឺសំដៅទៅលើវត្ថុរឹង សារធាតុរឹង ផលិតផល ឬរបស់កំទេចកំទី ដែលលែងត្រូវការប្រើប្រាស់ ហើយដែលត្រូវបានគេបោះបង់ចោល មានបំណងនឹងបោះបង់ចោល ឬតំរូវអោយបោះបង់ចោល ។

ខ- "**សំរាម**" គឺជាផ្នែកមួយនៃសំណល់រឹង ដែលពុំមានផ្ទុកជាតិពុល ឬសារធាតុបង្កគ្រោះថ្នាក់ ហើយត្រូវបញ្ចេញពីលំនៅដ្ឋាន អាគារសាធារណៈ រោងចក្រ ទីផ្សារ សណ្ឋាគារ អាគារពាណិជ្ជកម្ម ភោជនីយដ្ឋាន មធ្យោបាយដឹកជញ្ជូន កន្លែងកំសាន្ត ។ ល ។

គ- "**សំណល់ប្រកបដោយគ្រោះថ្នាក់**" គឺសំដៅទៅលើសារធាតុវិទ្យុសកម្ម ផ្ទុះ ពុល ឆេះ បង្កអោយមានជំងឺមហារីក ចំលងជំងឺ ធ្វើអោយរលាក ធ្វើអោយច្រេះ ធ្វើអុកស៊ីតកម្ម ឬ សារធាតុគីមីដទៃទៀត ដែលអាចនាំអោយមានគ្រោះថ្នាក់ដល់មនុស្ស សត្វ ឬមានការបំផ្លិចបំផ្លាញដល់រុក្ខជាតិ ទ្រព្យសម្បត្តិសាធារណៈ និងបរិស្ថាន ។ សំណល់ប្រកបដោយគ្រោះថ្នាក់អាចមានប្រភពពីលំនៅស្ថាន រោងចក្រឧស្សាហកម្ម សកម្មភាពកសិកម្ម សកម្មភាពអាជីវកម្ម និង សេវាកម្មអាជីវកម្មដ៏ ។ ល ។ ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ។

## ជំពូកទី ២
## ការគ្រប់គ្រងសំរាម

**មាត្រា ៤ .-** ក្រសួងបរិស្ថានត្រូវរៀបចំប្រកាស ស្ដីពីគោលការណ៍ណែនាំលើការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណសំរាម និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ដើម្បីធានាបាននូវការគ្រប់គ្រងសំរាម ប្រកបដោយសុវត្ថិភាព ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវរៀបចំផែនការគ្រប់គ្រងសំរាមនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន សំរាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង ។

**មាត្រា ៥ .-** ការអនុវត្តន៍ក្នុងការប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី១ នៃមាត្រា ៥ នេះ ត្រូវអនុលោមទៅតាមគោលការណ៍ណែនាំលើការគ្រប់គ្រងសំរាមប្រកបដោយសុវត្ថិភាព ដែលមានចែងក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៦ .-** ក្រសួងបរិស្ថាន ត្រូវធ្វើការត្រួតពិនិត្យលើការអនុវត្តន៍ក្នុងការបោះចោល ប្រមូល ដឹកជញ្ជូន ស្តុក កែច្នៃ កាត់បន្ថយបរិមាណ និងការចាក់ចោលសំរាមតាមបណ្តាខេត្ត-ក្រុង ។

**មាត្រា ៧ .-** ហាមឃាត់ជាដាច់ខាត ការបោះចោលសំរាមនៅតាមទីសាធារណៈ ឬការចាក់ចោលសំរាមខុសទីកន្លែង ដែលកំណត់ដោយអាជ្ញាធរ មានសមត្ថកិច្ច ។

**មាត្រា ៨ .-** ការវិនិយោគក្នុងស្រុកលើការសាងសង់កន្លែងចាក់ចោល ដុត ស្តុក ឬកែច្នៃសំរាម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន ។

**មាត្រា ៩ .-** ការនាំចេញសំរាមពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបានលុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

**មាត្រា ១០ .-** ហាមឃាត់ជាដាច់ខាត ការនាំសំរាមពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៣
## ការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

មាត្រា ១១ .-ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្ដីពីគោលការណ៍ណែនាំ លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ដើម្បីធានាបាននូវការគ្រប់គ្រងប្រកបដោយសុវត្ថិភាព ។

មាត្រា ១២ .-ក្រសួងបរិស្ថាន ត្រូវរៀបចំប្រកាសស្ដីពី កំរិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬ សារធាតុគ្រោះថ្នាក់នៅក្នុងសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលអាចអនុញ្ញាតអោយបោះបង់ចោល ដើម្បីធានាបាននូវការការពារសុខភាពមនុស្ស ការការពារគុណភាពបរិស្ថាន និងការអភិរក្សជីវចំរុះ ។

មាត្រា ១៣ .-ម្ចាស់សំណល់ ត្រូវទទួលខុសត្រូវក្នុងការទុកដាក់ ឬស្តុកទុកជាបណ្ដោះអាសន្ននូវសំណល់ ប្រកបដោយគ្រោះថ្នាក់របស់ខ្លួន តាមលក្ខណៈបច្ចេកទេសសមស្រប និងមានសុវត្ថិភាព ។

មាត្រា ១៤ .-ម្ចាស់សំណល់ ត្រូវធ្វើនិងផ្ញើរបាយការណ៍បីខែម្ដងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួន រួមមាន :

ក- ប្រភេទ និង បរិមាណសំណល់

ខ- វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្ដោះអាសន្ន

គ- វិធីសាស្ត្រក្នុងការសំអាតសំណល់ ឬ បំបាត់សំណល់ ។

មាត្រា ១៥ .-ការទុកដាក់ ស្តុក ដឹកជញ្ជូន និងការបោះចោល ឬ ចាក់ចោលសំណល់ ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុវត្តន៍ដាច់ដោយឡែកពីសំរាមធម្មតា ដែលនឹងមានចែងនៅក្នុងប្រកាសរបស់ក្រសួងបរិស្ថាន ។

ហាមឃាត់ជាដាច់ខាត ការបោះចោល ឬ ការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់នៅតាមទីសាធារណៈ ប្រព័ន្ធលូសាធារណៈ ប្រភព ឬ បណ្ដាញផ្លូវទឹក តំបន់ជនបទ និងតំបន់ព្រៃភ្នំ ។

មាត្រា ១៦ .-ការប្រមូល ដឹកជញ្ជូន ស្តុក និងការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ តាមលំនៅស្ថាន ទីផ្សារ គ្លីនិក សម្ភព មន្ទីរពេទ្យ សណ្ឋាគារ ភោជនីយដ្ឋាន និងអាគារសាធារណៈ គឺជាសមត្ថកិច្ចរបស់អាជ្ញាធរខេត្ត-ក្រុង ។

ការអនុវត្តន៍វាក្យខ័ណ្ឌទី១ នៃមាត្រា១៦ នេះ ត្រូវអនុលោមទៅតាមប្រកាសរបស់ក្រសួងបរិស្ថាន ស្ដីពីគោលការណ៍ណែនាំលើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់ ។

មាត្រា ១៧ .-ការដឹកជញ្ជូន ឬ សាងសង់ទីកន្លែងចាក់ ឬទីកន្លែងស្តុកសំណល់ប្រកបដោយគ្រោះថ្នាក់ ដែលមានប្រភពពីរោងចក្រសហគ្រាស និងមូលដ្ឋានផលិតកម្ម ត្រូវមានការអនុញ្ញាតពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ១៨ .-ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែងចាក់ ឬស្តុកសំណល់ ប្រកបដោយគ្រោះថ្នាក់ ត្រូវធ្វើនិងផ្ញើរបាយការណ៍បីខែម្ដងទៅក្រសួងបរិស្ថាន នូវរបាយការណ៍ដែលទាក់ទងទៅនឹងសំណល់ដែលបានដឹកយកមកចាក់ចោល ឬស្តុកនៅកន្លែងរបស់ខ្លួន រួមមាន :

ក- ប្រភេទ និង បរិមាណសំណល់

ខ- ប្រភពដើមរបស់សំណល់

គ- ការដឹកជញ្ជូន និង មធ្យោបាយវេចខ្ចប់

ឃ- ដំណើរការ និងការគ្រប់គ្រង សំណល់នៅក្នុងទីកន្លែងរបស់ខ្លួន ។

មាត្រា ១៩ .-ការវិនិយោគលើការធ្វើប្រព្រឹត្តកម្មសំអាត ឬដុតសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវមានការឯកភាពពីក្រសួងបរិស្ថាន ជាមុនសិន ។

មាត្រា ២០ .-ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ពីព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសក្រៅ អាចនឹងប្រព្រឹត្តទៅបាន លុះត្រាណាមានការឯកភាពពីក្រសួងបរិស្ថាន និងមានអាជ្ញាប័ណ្ណនាំចេញរបស់ក្រសួងពាណិជ្ជកម្ម ព្រមទាំងលិខិតអនុញ្ញាតអោយនាំចូលរបស់សាមីប្រទេស ជាមុនសិន ។

ការនាំចេញនូវសំណល់ប្រកបដោយគ្រោះថ្នាក់ ត្រូវអនុលោមតាមបទបញ្ញត្តិ និងគោលការណ៍នៃអនុសញ្ញាអន្តរជាតិបាសែល ស្តីពីការត្រួតពិនិត្យការដឹកជញ្ជូនអន្តរជាតិ និងការបោះបង់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ឆ្នាំ ១៩៨៩ ដែលចូលជាធរមាន នៅថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ១៩៩២ ។

មាត្រា ២១ .-ហាមឃាត់ជាដាច់ខាត ការនាំចូលសំណល់ប្រកបដោយគ្រោះថ្នាក់ ពីប្រទេសក្រៅ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ៤

## ការត្រួតពិនិត្យ និងការធ្វើអធិការកិច្ច

## លើការគ្រប់គ្រងសំណល់ប្រកបដោយគ្រោះថ្នាក់

មាត្រា ២២ .-ការត្រួតពិនិត្យលើការវេចខ្ចប់ ទុកដាក់ ស្តុក ដឹកជញ្ជូន កែច្នៃ ដុត ធ្វើប្រព្រឹត្តកម្ម សំអាតជាតិពុល និងការចាក់ចោលសំណល់ប្រកបដោយគ្រោះថ្នាក់ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

មាត្រា ២៣ .-ក្រសួងបរិស្ថាន ត្រូវចុះយកគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ នៅគ្រប់គោលដៅដែលមានចែងក្នុងមាត្រា ២២ នៃអនុក្រឹត្យនេះ ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា ២៣ នេះ ត្រូវចូលរួមសហការ និងបង្កលក្ខណៈងាយស្រួលដល់មន្ត្រីបរិស្ថាន ដែលចុះយកគំរូតាង ដើម្បីបំពេញការងារតាមលក្ខណៈបច្ចេកទេស ។

មាត្រា ២៤ .- ការវិភាគគំរូតាងសំណល់ប្រកបដោយគ្រោះថ្នាក់ ក្នុងពេលចុះត្រួតពិនិត្យ ឬ ធ្វើអធិការកិច្ច ត្រូវយកទៅធ្វើនៅក្នុងមន្ទីរពិសោធន៍ ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា ២៣ នៃអនុក្រឹត្យនេះ អាចសុំធ្វើការវិភាគគំរូតាងសំណល់របស់ខ្លួន នៅតាមមន្ទីរពិសោធន៍រដ្ឋ ឬឯកជនដទៃទៀត ដែលមានការទទួលស្គាល់ជាផ្លូវការ ហើយដែលមន្ទីរពិសោធន៍នោះអនុវត្តនូវវិធីសាស្ត្រវិភាគ ដូចដែលបានអនុវត្តក្នុងមន្ទីរពិសោធន៍របស់ក្រសួងបរិស្ថាន ។

ម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ដែលមានចែងនៅក្នុងវាក្យខ័ណ្ឌទី១ នៃមាត្រា ២៣ នៃអនុក្រឹត្យនេះ ត្រូវបង់ថ្លៃវិភាគសំណល់របស់ខ្លួន តាមបញ្ជីចំនួនទឹកប្រាក់ ដែលបានកំណត់ជាមុន ដោយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

ចំណូលនេះត្រូវបញ្ចូលទៅក្នុងថវិកាជាតិ ដើម្បីផ្តល់ជូនទៅគណនីមូលនិធិទាយជ្ជទានបរិស្ថាន ។

មាត្រា ២៥ .-ក្នុងករណីដែលរកឃើញថា មានការលួចចាក់ចោល ឬបោះចោលសំណល់ប្រកបដោយគ្រោះថ្នាក់ ដោយគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ក្រសួងបរិស្ថាន សហការជាមួយស្ថាប័នពាក់ព័ន្ធ ត្រូវចុះធ្វើអធិការកិច្ច ដល់ទីកន្លែងនោះ ដោយអនុវត្តតាមនីតិវិធីដែលមានចែងខាងក្រោម :

ក- បង្ហាញអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្មរបស់ខ្លួន នៅពេលចូលក្នុងបរិវេណ ឬ ទីកន្លែងនោះ ដើម្បីធ្វើអធិការកិច្ច និងយកគំរូតាង ។

ខ- ត្រូវធ្វើនៅនឹងកន្លែង នូវកំណត់ហេតុ និងរបាយការណ៍ដំបូងនៃការត្រួតពិនិត្យ ឬ ការយកគំរូតាង ដោយត្រូវមានសាក្សីចូលរួមក្នុងករណីចាំបាច់ ។

គ- ត្រូវសាកសួរ និងតំរូវអោយម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវទីកន្លែង ផ្តល់នូវពត៌មាន ឬឯកសារនានា ដែលពាក់ព័ន្ធសំរាប់ប្រើប្រាស់ក្នុងការធ្វើរបាយការណ៍ ឬកំណត់ហេតុ និងសំរាប់ជាវត្ថុតាង ។

ឃ-ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ។

មាត្រា ២៦ .- ក្នុងករណីមានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថា មានស្តុកទុក ឬការចាក់ចោលនូវសំណល់ប្រកបដោយគ្រោះថ្នាក់ បណ្តាលអោយប៉ះពាល់ទៅដល់សុខភាពមនុស្ស សត្វ ឬ ទ្រព្យសម្បត្តិសាធារណៈ ឬ បង្កអោយមានការបំពុលបរិស្ថាន ក្រសួងបរិស្ថាន ត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់ ហើយត្រូវជូនពត៌មានទៅបណ្តាស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ។

## ជំពូកទី ៥

## ទោសបញ្ញត្តិ

មាត្រា ២៧ .-ការរំលោភល្មើសទៅនឹងអនុក្រឹត្យនេះ នឹងត្រូវទទួលពិន័យ និងការផ្តន្ទាទោស ដោយយោងទៅតាមមាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ និង មាត្រា ២៥ ជំពូកទី ៩ នៃច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

មាត្រា ២៨ .-មន្ត្រី ឬ ភ្នាក់ងារអធិការកិច្ចបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទបញ្ជារបស់ក្រសួង ឬ រួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

មាត្រា ២៩ .-កំណត់ហេតុ និងការធ្វើបណ្តឹង ចំពោះជនទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយនៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់មន្ត្រីក្រសួងបរិស្ថាន ។

# ជំពូកទី ៦
## អវសានបញ្ញត្តិ

មាត្រា ៣០ .-បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣១ .-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និង ស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

មាត្រា ៣២ .-អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

បានយកសេចក្តីជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីក្រសួងបរិស្ថាន

ហត្ថលេខា

ម៉ុក ម៉ារ៉េត

***

## តារាងឧបសម្ព័ន្ធ
## ប្រភេទសំណល់ប្រកបដោយគ្រោះថ្នាក់

១- សំណល់សរសៃអំបោះ និង កំទេចក្រណាត់ដែលមានពណ៌ (ក្នុងករណីយកទៅដុត)

២- សំណល់កំទេចក្រដាស ដែលសល់ពីការផលិតម្សៅក្រដាស

៣- សំណល់ភក់ ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសំអាតសំណល់រាវ និង ទឹកល្បូ

៤- សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឡ ឧស្សាហកម្ម

៥- សំណល់ប្លាស្ទិច " ប៉ូលីវីនីលក្លរ "

៦- សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីពប៊ីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល។

៧- សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុ ប៉ូលីម៉ែប៉ុយទីលិន

៨- សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៩- សំណល់ដែលមានផ្ទុកជាតិអាស៊ីត

១០- សំណល់ដែលមានផ្ទុកជាតិបាស

១១- សំណល់ លោហៈ និងសមាសធាតុរបស់វា រួមមាន :

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | ប៉ារីយ៉ូម (Ba) | កូបាល់ (Co) |

| | | | |
|---|---|---|---|
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាលយ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរីយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារត (Hg) | កាត់មូម (Cd) | ដែក (Fe) | |

១២- លាំអងផ្សេង និងធូលីដែលកើតមានក្នុងការលីតអាតផ្សេងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១៣- សំណល់ អំពូលអគ្គិសនី និង បន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១៤- សំណល់អាគុយ និងថ្មពិល

១៥- សំណល់ថ្នាំលាប និង ថ្នាំជ្រលក់ពណ៌ និងសំភារៈវេចខ្ចប់ថ្នាំពណ៌

១៦- សំណល់បានមកពីការផលិត និង ការប្រើប្រាស់ទឹកខ្មៅបោះពុម្ព

១៧- សំណល់ គ្រឿងផ្ទុះ

១៨- សំណល់ ដែលនាំអោយមានការចំលងមេរោគ ឬ ជំងឺ

១៩- សំណល់ ដែលសល់ពីការផលិតថ្នាំពុល កសិកម្ម និងសំភារៈវេចខ្ចប់

២០- សំណល់ផេះនៃឡដុតសំរាម សំណលរឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

២១- ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

២២- សំណល់ហ្វីល ដូចជាហ្វីលភាពយន្ត វីដេអូ ហ្វីលកាសែតចំរៀង ហ្វីលថតរូប និងហ្វីលថតសរីរាង្គមនុស្ស តាមមន្ទីរពេទ្យ ។

២៣- សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសំអាតដីកខ្វក់ ឬដីខូចគុណភាព

២៤- សំណល់ដែលបានមកពីការផលិតឱសថ និង ឱសថដែលខូចគុណភាព

២៥- សំណល់ដែលជាសមាសធាតុសរីរាង្គហ្វូយអរីន

២៦- សំណល់ ដែលជាសមាសធាតុស៊ីអានីត

២៧- សំណល់ ដែលជាសមាសធាតុអាសបេតូស

២៨- សំណល់ ដែលជាសមាសធាតុផេណុល ($C_6H_5OH$)

២៩- សំណល់ ដែលជាសមាសធាតុអេទែ (R-COO-$R_1$)

៣០- សំណល់ ដែលជាសារធាតុសរីរាង្គរំលាយដែលមានអាឡូសែន និងគ្មានអាឡូសែន

៣១- សំណល់ ដែលជាសមាសធាតុ ឌីអុកស៊ីន និងបួរ៉ាន

៣២- សំណល់ ធាតុវិទ្យុសកម្ម

៣៣- សារធាតុ ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសំអាតសំណល់ ដែលមានចែងពីចំនុចទី១ ដល់ទី ៣២

★★★

## អនុក្រឹត្យ លេខ ៣៧ អនក្រ.បក
### ស្តីពី
### ការកែសំរួលអនុក្រឹត្យលេខ ២៩ អនក្រ បក ចុះថ្ងៃទី២០ ខែ ឧសភា ឆ្នាំ ១៩៩៨ ស្តីពីសមាសភាព និងការប្រព្រឹត្តិទៅនៃគណៈកម្មការប្រឹក្សាការងារ

***

### រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ចស / រកម / ០៣៩៧ / ០១ ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ១៩៩៧ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការងារ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា

### សំរេច

**មាត្រា ១ .–** មាត្រា ១ មាត្រា ៣ មាត្រា ៤ មាត្រា ៥ មាត្រា ៨ មាត្រា ៩ និង មាត្រា ១០ នៃអនុក្រឹត្យលេខ ២៩ អនក្រ បក ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ១៩៩៨ ត្រូវបានកែសំរួលដូចតទៅ ៖

**មាត្រា១ថ្មី .–** បង្កើតគណៈកម្មការប្រឹក្សាការងារមួយនៅអមក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលមានបេសកកម្មជាអាទិ៍ សិក្សាស្រាវជ្រាវរាល់បញ្ហាដែលទាក់ទងនឹងការងារ មុខរបរនៃកម្មករ និយោជិត ប្រាក់ឈ្នួល ការអប់រំវិជ្ជាជីវៈ ចលនាកំលាំងពលកម្មក្នុងប្រទេស ទេសន្តរប្រវេសន៍ ការរៀបចំអោយរិតតែប្រសើរឡើងនូវល័ក្ខខ័ណ្ឌខាងសំភារៈ និង ខាងស្មារតីនៃកម្មករ និយោជិត ហើយនិងបញ្ហាអនាម័យ និងសន្តិសុខការងារ ។

**មាត្រា៣ថ្មី .–** គណៈកម្មការប្រឹក្សាការងារមានសមាសភាពដូចតទៅ :

- រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ឬ តំណាង — ជាប្រធាន
- តំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ — មួយរូបជាសមាជិក
- តំណាង ក្រសួងពាណិជ្ជកម្ម — មួយរូបជាសមាជិក
- តំណាង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល — មួយរូបជាសមាជិក
- តំណាង ក្រសួង សុខាភិបាល — មួយរូបជាសមាជិក
- តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ — មួយរូបជាសមាជិក

- តំណាង ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន មួយរូបជាសមាជិក
- តំណាង ក្រសួង បរិស្ថាន មួយរូបជាសមាជិក
- តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន មួយរូបជាសមាជិក
- តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា មួយរូបជាសមាជិក
- តំណាង អង្គការសហជីពកម្មករ និយោជិតដែលមានភាព ជាតំណាងជាងគេបំផុតក្នុងថ្នាក់ជាតិ ប្រាំរូប ជាសមាជិក
-តំណាងអង្គការនិយោជកដែលមានភាពជាតំណាងជាងគេបំផុតក្នុង ថ្នាក់ជាតិ ប្រាំរូប ជាសមាជិក

គណៈកម្មការនេះត្រូវបោះឆ្នោតជ្រើសរើស អនុប្រធានពីររូប គឺម្នាក់ក្នុងចំណោម ៥នាក់ ដែលជាតំណាងនៃអង្គការសហជីពកម្មករ និយោជិត និងម្នាក់ទៀតក្នុងចំណោម ៥នាក់ ដែលជាតំណាងអង្គការនិយោជក ។

**មាត្រា៤ថ្មី .–** គណៈកម្មការប្រឹក្សាការងារ ត្រូវមានសមាជិកបម្រុង ដែលមានចំនួនស្មើគ្នានឹងចំនួនសមាជិកពេញសិទ្ធិ ។ សមាជិកពេញសិទ្ធិ និងសមាជិកបម្រុង របស់គណៈកម្មការប្រឹក្សាការងារ ដែលឧទ្ទេសនាមដោយក្រសួងពាក់ព័ន្ធ ដោយអង្គការសហជីពកម្មករ និយោជិត និងអង្គការនិយោជក ត្រូវតែងតាំងដោយប្រកាសរបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ។ គណៈកម្មការប្រឹក្សាការងារ អាចអញ្ជើញតំណាងក្រសួង និង ស្ថាប័ន អង្គការជាតិ និងអន្តរជាតិពាក់ព័ន្ធផ្សេងទៀតចូលរួមប្រជុំ ដើម្បីផ្តល់យោបល់ក្នុងករណីចាំបាច់ ។

**មាត្រា៥ថ្មី .–** សមាជិកគណៈកម្មការប្រឹក្សាការងារ មានអាណត្តិពីរឆ្នាំ ។ សមាជិកបម្រុងត្រូវចូលរួមប្រជុំជំនួសសមាជិកពេញសិទ្ធិដែលអវត្តមាន ។ ករណីដែលសមាជិកពេញសិទ្ធិទទួលមរណភាព លាលែងដកហូត ឬ ផ្លាស់ប្តូរពីតំណែងដោយប្រការណាមួយ ដោយក្រសួង ឬ អង្គការពាក់ព័ន្ធ សមាជិកបម្រុងនឹងក្លាយជាសមាជិកពេញសិទ្ធិដោយស្វ័យប្រវត្តិ រហូតដល់ចប់អាណត្តិ ។ ក្នុងពេលនេះ ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា អាចស្នើអោយ ក្រសួង ឬ អង្គការពាក់ព័ន្ធ ឧទ្ទេសនាមបេក្ខជនថ្មីដើម្បីតែងតាំងជាសមាជិកបម្រុង ជំនួសសមាជិកបម្រុងមុន បើពិនិត្យឃើញថាចាំបាច់ ។

**មាត្រា៨ថ្មី .–** ការសំរេចលើបញ្ហាអ្វីមួយ ក្នុងនោះមានរួមបញ្ចូលទាំងការបោះឆ្នោតជ្រើសរើសអនុប្រធានគណៈកម្មការផង ត្រូវអនុម័តយកតាមសំលេងភាគច្រើន នៃចំនួនសមាជិកដែលបានបោះឆ្នោត ។ ករណីទទួលបានសំលេងស្មើគ្នា សំលេងប្រធានមានឧត្តមានុភាព ។

រាល់ការបោះឆ្នោតត្រូវធ្វើឡើងជាចំហរ លើកលែងតែការបោះឆ្នោតដើម្បីជ្រើសរើស អនុប្រធានគណៈកម្មការដែលត្រូវធ្វើដោយសំងាត់ ។

**មាត្រា៩ថ្មី .–** គណៈកម្មការប្រឹក្សាការងារ ត្រូវមានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយដែល រៀបចំដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និងយុវនីតិសម្បទា ។

**មាត្រា២ .–** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ពាក់ព័ន្ធ និងគ្រប់អង្គការ វិជ្ជាជីវៈ ដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

បានជំរាបជូនសម្តេចនាយករដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

និងយុវនីតិសម្បទា

ហត្ថលេខា

**អ៊ិត សំហេង**

★★★

**អនុក្រឹត្យ លេខ ៣៨ អនក្រ.បក**

**ស្តីពី**

**ការគ្រប់គ្រង និង ការត្រួតពិនិត្យការនាំចូល ការផលិត ការលក់ ការជួញដូរ ការចែកចាយ និង ការ ចុះប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ

-បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃក្រសួងមហាផ្ទៃ

-បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ / បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៩ ស្តីពីការកែសំរួលរចនាសម្ព័ន្ធចាត់តាំង ក្រសួងការពារជាតិ

-បានក្រឹត្យលេខ១១ ក្រ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ១៩៩២ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការផ្តន្ទាទោស ការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ញា

-បានឃើញច្បាប់ក្របខណ្ឌអន្តរកាល

-បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**មាត្រា ១ .-** អនុក្រឹត្យនេះមានគោលដៅបង្ការ និងបង្ក្រាប ដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យ ការកាន់កាប់ ការស្តុក ការនាំចូល ការផលិត ការលក់ ការទិញដូរ ការចែកចាយ និងការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលគ្មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

**មាត្រា២ .-** ចាត់ទុកជាអាវុធ ជាតិផ្ទុះ រួមមាន :

១-កាំភ្លើងវែង កាំភ្លើងខ្លីគ្រប់ប្រភេទ ។

២-កាំភ្លើង ប្រភេទឧស្ម័នរៀបទឹកភ្នែក ឬ សន្លប់ ឬ ឧស្ម័នពុល ។

៣-កាំភ្លើង ស្វ័យប្រវត្តិ ពាក់កណ្តាលស្វ័យប្រវត្តិគ្រប់ប្រភេទ ។

៤-កាំភ្លើង ខ្ទប់សំលេង ឬ ឧបករណ៍ខ្ទប់សំលេង ។

៥-រ៉ុកកែតគ្រប់ប្រភេទ ។

៦-អាវុធគីមីគ្រប់ប្រភេទ ។

៧-អាវុធជីវសាស្ត្រគ្រប់ប្រភេទ ។

៨-ដំបងឆក់គ្រប់ប្រភេទ ។

៩-គ្រាប់បែក គ្រាប់មីនគ្រប់ប្រភេទ ។

១០-ជាតិផ្ទុះ ឬ សារធាតុផ្ទុះគ្រប់ប្រភេទ។

១១-គ្រាប់កាំភ្លើងគ្រប់ប្រភេទ ។

**មាត្រា៣ .-** អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ មិនអាចជាកម្មវត្ថុនៃកម្មសិទ្ធិឯកជនបានឡើយ ។

ជនណាដែលសព្វថ្ងៃនេះមានអាវុធ ជាតិផ្ទុះ ទោះជាទុកនៅទីកន្លែងណាក៏ដោយ ត្រូវយកអាវុធជាតិផ្ទុះនោះមកប្រគល់អោយអាជ្ញាធរមានសមត្ថកិច្ច តាមការកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និងក្រសួងការពារជាតិ ។

មាត្រា៤ .- ហាមឃាត់ដាច់ខាត ការលក់ ការទិញដូរ ការធ្វើអំណោយ ការស្តុកទុកក្នុងផ្ទះ ឬទីកន្លែងណាផ្សេងទៀត នូវអាវុធ ជាតិផ្ទុះដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា៥ .- ការនាំចូល ការផលិតអាវុធ ជាតិផ្ទុះគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល :

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធ ជាតិផ្ទុះនោះប្រើអោយវិស័យការពារជាតិ ។

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធ ជាតិផ្ទុះនោះប្រើអោយវិស័យសន្តិសុខជាតិ ។

ការដឹកជញ្ជូនអាវុធ ជាតិផ្ទុះគ្រប់ប្រភេទ នៅផ្ទៃក្នុងប្រទេស ជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ បើអាវុធ ជាតិផ្ទុះនោះប្រើអោយវិស័យសន្តិសុខជាតិ ឬ ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ បើអាវុធ ជាតិផ្ទុះ នោះប្រើអោយវិស័យការពារជាតិ ។

## ជំពូកទី ២

## ការគ្រប់គ្រង និង ការត្រួតពិនិត្យ ការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ

មាត្រា៦ .- ក្រសួងការពារជាតិមានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រង និងការត្រួតពិនិត្យការប្រើប្រាស់ អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ ក្នុងកងយោធពលខេមរភូមិន្ទ និង កងរាជអាវុធហត្ថ រួមទាំងអាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ដែលបានរក្សាទុកក្នុងឃ្លាំង ។

មាត្រា៧ .- ក្រសួងមហាផ្ទៃ មានភារកិច្ចទទួលខុសត្រូវលើការងារគ្រប់គ្រង និងការត្រួតពិនិត្យការប្រើប្រាស់ អាវុធនិងជាតិផ្ទុះគ្រប់ប្រភេទ ក្នុងកងកំលាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងជីវពល និង កងសន្តិសុខ ធនាគារជាតិនៃកម្ពុជា រួមទាំងអាវុធជាតិផ្ទុះគ្រប់ប្រភេទដែលបានរក្សាទុកក្នុងឃ្លាំង ។

មាត្រា៨ .- ការនាំចូល ការប្រើប្រាស់ ការដឹកជញ្ជូន ការស្តុកទុកក្នុងឃ្លាំង នូវជាតិផ្ទុះ ឬសារធាតុផ្ទុះគ្រប់ប្រភេទ សំរាប់ប្រើការអោយការផលិត ឬ សេវាកម្មសាធារណៈ ត្រូវមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ។

នីតិវិធី និងបែបបទនៃការសុំលិខិតអនុញ្ញាតនេះ ត្រូវកំណត់ដោយប្រកាសក្រសួងមហាផ្ទៃ ។

## ជំពូកទី ៣

## អំពីសមត្ថកិច្ចក្នុងការចេញលិខិត
## អនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ

មាត្រា៩ .- ក្រសួងការពារជាតិ មានសិទ្ធិផ្តល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ ចំពោះកងយោធពលខេមរភូមិន្ទ និង កងរាជអាវុធហត្ថ ។

មាត្រា១០ .- ក្រសួងមហាផ្ទៃ មានសិទ្ធិផ្តល់លិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះគ្រប់ប្រភេទ ចំពោះកងកំលាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងជីវពល និង កងសន្តិសុខធនាគារជាតិ នៃ កម្ពុជា ។

មាត្រា១១ .- នីតិវិធី និង លក្ខខ័ណ្ឌ នៃការសុំលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ និង ជាតិផ្ទុះ សំរាប់កង យោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងកំលាំងនគរបាលជាតិ មន្ត្រីរាជការស៊ីវិល កងជីវពល

និងកងសន្តិសុខធនាគារជាតិនៃកម្ពុជា ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ។

## ជំពូកទី៤

## សិទ្ធិប្រើប្រាស់ កាំភ្លើងខ្លីជាលក្ខណៈផ្ទាល់ខ្លួន

**មាត្រា១២ .-** មន្ត្រីរាជការស្ថាប័នស៊ីវិល ដែលអាចអនុញ្ញាតអោយប្រើប្រាស់កាំភ្លើងខ្លីយកតាមខ្លួនមួយនាក់មួយដើម ជាលក្ខណៈផ្ទាល់ខ្លួនបានតាមការកំណត់ដូចខាងក្រោម :

-នៅស្ថាប័ននីតិបញ្ញត្តិ សមាជិកព្រឹទ្ធសភា សមាជិករដ្ឋសភា សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

-នៅសាលាជំរះក្តី គឺប្រធាន និង អគ្គព្រះរាជអាជ្ញាតុលាការកំពូល ។

-នៅក្រសួង ស្ថាប័ន ចាប់ពីថ្នាក់អគ្គនាយកឡើងទៅ ។

-នៅខេត្ត-ក្រុង រាជធានីភ្នំពេញ ចាប់ពីអភិបាលរងខេត្ត ក្រុងឡើងទៅ ។

-នៅស្រុក ខ័ណ្ឌ គឺ អភិបាលស្រុក ខ័ណ្ឌ ។

**មាត្រា១៣ .-** កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ និងកងកំលាំងនគរបាលជាតិ អាចអនុញ្ញាតអោយប្រើប្រាស់កាំភ្លើងខ្លី យកតាមខ្លួនមួយនាក់មួយដើមជាលក្ខណៈផ្ទាល់ខ្លួនបាន ចាប់ពីថ្នាក់វរសេនីយ៍ឯកឡើងទៅ ។

**មាត្រា១៤ .-** ចំពោះកងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងកំលាំងនគរបាលជាតិ ក្រៅពីការកំណត់ក្នុងមាត្រា១៣នៃអនុក្រឹត្យនេះ អាចប្រើប្រាស់អាវុធ ជាតិផ្ទុះបានតែក្នុងពេលប្រតិបត្តិការ ។

ក្នុងពេលប្រតិបត្តិការនេះ ត្រូវមានភ្ជាប់ជាមួយលិខិតបញ្ជាបេសកកម្ម និងមានលិខិតអនុញ្ញាតប្រើប្រាស់អាវុធជាតិផ្ទុះជាលក្ខណៈសមូហភាព ។

-ចំពោះលិខិតបញ្ជាបេសកកម្ម នៃកងយោធពលខេមរភូមិន្ទ ត្រូវចុះហត្ថលេខាដោយខុទ្ទកាល័យក្រសួងការពារជាតិ ឬ ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ឬមេបញ្ជាការជើងគោក ឬ មេបញ្ជាការជើងទឹក ឬ មេបញ្ជាការជើងអាកាស ឬមេបញ្ជាការកងរាជអាវុធហត្ថ ឬ មេបញ្ជាការយោធភូមិភាគ ឬ មេបញ្ជាការតំបន់ប្រតិបត្តិការសឹករង ។

សមត្ថកិច្ចចុះហត្ថលេខាលើលិខិតបញ្ជាបេសកកម្ម នៃកងយោធពលខេមរភូមិន្ទ ដែលពុំមានចែងខាងលើ ត្រូវកំណត់ដោយអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ ។

-ចំពោះលិខិតបញ្ជាបេសកកម្មនៃកងកំលាំងនគរបាលជាតិ កងសន្តិសុខធនាគារជាតិនៃកម្ពុជា ត្រូវចុះហត្ថលេខាដោយអគ្គនាយកនគរបាលជាតិ ឬ ស្នងការនគរបាលខេត្ត ក្រុង ។

ក្រោយពេលចប់កិច្ចប្រតិបត្តិការភ្លាម ត្រូវយកអាវុធ ជាតិផ្ទុះ រួមទាំងលិខិតប្រើប្រាស់អាវុធ ជាតិផ្ទុះនោះមករក្សាទុកនៅតាមអង្គភាពសាមី ។

ករណីនៃកិច្ចប្រតិបត្តិការដែលចាំបាច់ ត្រូវប្រើប្រាស់អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ។

មាត្រា១៥ .- ជនបរទេសគ្មានសិទ្ធិប្រើប្រាស់អាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ។

មាត្រា១៦ .- កាំភ្លើងវែងមិនអនុញ្ញាតអោយប្រើប្រាស់ជាលក្ខណៈផ្ទាល់ខ្លួនឡើយ ។

មាត្រា១៧ .- ហាមយកអាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ចូលក្នុងរាជធានីភ្នំពេញ លើកលែងតែមានការអនុញ្ញាតពីក្រសួងមហាផ្ទៃ ឬ ក្រសួងការពារជាតិ ។

បែបបទ និង លក្ខខណ្ឌនៃការសុំអនុញ្ញាតយកអាវុធ ជាតិផ្ទុះគ្រប់ប្រភេទ ចូលរាជធានីភ្នំពេញ និង ចំនួនប៉ុស្ដិ៍ទទួលផ្ញើអាវុធជាតិផ្ទុះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួង របស់ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ។

## ជំពូកទី ៥

## ទោសបញ្ញត្តិ

មាត្រា១៨ .- ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារតាមច្បាប់ ស្ដីពីការផ្ដន្ទាទោសការកាន់អាវុធ និងការពាក់សំលៀកបំពាក់ឯកសណ្ឋានដោយខុសពីបទបញ្ជានិងច្បាប់ព្រហ្មទណ្ឌអន្តរកាល ចំពោះជនណាដែលបានប្រព្រឹត្តល្មើស នឹងចំណុចណាមួយខាង ក្រោមនេះ :

១-ជនណាប្រព្រឹត្តល្មើសនឹងមាត្រា៣ មាត្រា៤ មាត្រា៩ មាត្រា១២ មាត្រា១៣ មាត្រា១៤ មាត្រា១៥ និង មាត្រា១៦ នៃអនុក្រឹត្យនេះ ។

២-ជនណាដែលនាំចូល លក់ ទិញដូរ កាន់កាប់ រក្សាទុក យកអាវុធជាតិផ្ទុះ ឬ គ្រាប់រំសេវតាមខ្លួន ដោយគ្មានលិខិតអនុញ្ញាត ។

៣-ជនណាដែលបានផ្ដល់អោយ បានអោយខ្ចី ឬ បានជួលអាវុធជាតិផ្ទុះ ឬ គ្រាប់រំសេវដែលខ្លួនមាន ទៅជនដទៃ ។

៤-ជនណាបានដកកាំភ្លើងជួសអ្នកដទៃ ឬបាញ់គំរាមកំហែងអ្នកដទៃ ឬ បាញ់ខ្យល់ ភ្លេង ពាះ ឬ បាញ់លេង ឬការបាញ់សាកល្បងក្រៅពីកន្លែងបាញ់សាកដែលកំណត់ដោយក្រសួងមហាផ្ទៃ ឬ សួង ការពារជាតិ ។

មាត្រា១៩ .- ជនណាមានលិខិតអនុញ្ញាតយកអាវុធតាមខ្លួនហើយធ្វើអោយបាត់គ្រាប់កាំភ្លើង ឬមានចំនួនគ្រាប់កាំភ្លើងល្មើសពីការអនុញ្ញាតអោយប្រើប្រាស់ដោយគ្មានមូលហេតុត្រឹមត្រូវ ជននោះត្រូវដកហូតអាវុធ និងលិខិតអនុញ្ញាតនោះមកវិញ ។

ចំនួនគ្រាប់កាំភ្លើងដែលអនុញ្ញាតអោយប្រើប្រាស់ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរបស់ ក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិ ។

មាត្រា២០ .- វត្ថុតាងនៃបទល្មើស ដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវរឹបអូសទុកជាសម្បត្តិរដ្ឋ និងត្រូវបញ្ជូន អោយទៅអគ្គនាយកដ្ឋាននគរបាលជាតិ ដើម្បីគ្រប់គ្រង លើកលែងតែអាវុធធុនធ្ងន់ ដែលជាសំភារៈ សឹក ត្រូវបញ្ជូនទៅអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ ដើម្បីគ្រប់គ្រង ។

មាត្រា២១ .- ត្រូវដកហូតអាវុធ និងលិខិតអនុញ្ញាតអោយប្រើប្រាស់អាវុធ ព្រមទាំងមិនអោយប្រើប្រាស់អាវុធ ជាស្ថាពរពីជនណាដែល បានយកអាវុធ ឬ ជាតិផ្ទុះទៅបង្កបទល្មើស ។

មាត្រា២២ .- អាជ្ញាធរមានសមត្ថកិច្ចណាចេញ លិខិតអោយប្រើប្រាស់អាវុធខុសពីការកំណត់ ដូចមានចែងក្នុង មាត្រា១២ មាត្រា១៣ និង មាត្រា ១៤ នៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

## ជំពូកទី ៦

## អន្តរប្បញ្ញត្តិ

មាត្រា២៣ .- ក្រោយអនុក្រឹត្យនេះចូលជាធរមាន ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ត្រូវពិភាក្សាពីការផ្ទេរ កងជីវពលពីក្រសួងការពារជាតិ មកក្រសួងមហាផ្ទៃ ។

មាត្រា២៤ .- ជនដែលមានសិទ្ធិប្រើប្រាស់កាំភ្លើងខ្លីជាលក្ខណៈផ្ទាល់ខ្លួន តាមការកំណត់ដូចមានចែងក្នុងមាត្រា ១២ និង មាត្រា១៣ នៃអនុក្រឹត្យនេះត្រូវមកសុំលិខិតអនុញ្ញាតប្រើប្រាស់អាវុធពីក្រសួងមហាផ្ទៃ ចំពោះនគរបាលជាតិ និងមន្ត្រីរាជការស៊ីវិល ឬ ក្រសួងការពារជាតិ ចំពោះកងយោធពលខេមរភូមិន្ទ និងកងរាជអាវុធហត្ថ ក្នុងរយៈពេលយ៉ាងយូរពីរខែក្រោយ អនុក្រឹត្យនេះចូលជាធរមាន ។

ក្នុងករណីមិនអនុវត្តត្រឹមត្រូវតាមការកំណត់ខាងលើនេះ សាមីជនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ នឹងត្រូវរឹបអូសអាវុធនោះទុកជាសម្បត្តិរដ្ឋ ។

មាត្រា២៥ .- ក្រោយអនុក្រឹត្យនេះចូលជាធរមាន រាល់ក្លឹបបាញ់ស៊ីប ក្លឹបបាញ់កំសាន្តបែបកីឡាទាំងអស់ ត្រូវបិទ ។

ចំពោះអាវុធជាតិផ្ទុះគ្រប់ប្រភេទ ដែលមាននៅក្នុងក្លឹបទាំងអស់ ត្រូវយកមកប្រគល់អោយអគ្គនាយកដ្ឋាននគរបាលជាតិ ដើម្បីរក្សាទុកជាសម្បត្តិរដ្ឋ ។

## ជំពូកទី ៧

## អវសានប្បញ្ញត្តិ

មាត្រា២៦ .- អនុក្រឹត្យលេខ ៦២ អនក្រ-បក ចុះថ្ងៃទី៣១ ខែ កក្កដា ឆ្នាំ ១៩៩៥ និងបទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា២៧ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាល ខេត្ត-ក្រុង ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ហត្ថលេខា និងត្រា

ស ខេង យូ ហុកគ្រី

ទៀ បាញ់ អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ សេរីរ័ត្ន

★★★

# អនុក្រឹត្យ លេខ ១១៩ អនក្រ.តត

## ស្តីពី ការជូនមេដាយស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សាលាក្រុងភ្នំពេញ

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនសប្បុរសជនជប៉ុន ០៣រូប នៃអង្គការ JSRC ដែលបានមកជួយព្រះរាជាណាចក្រកម្ពុជា តាំងពីឆ្នាំ ១៩៩៥ រហូតដល់បច្ចុប្បន្ន ដើម្បីសាងសង់អាគារ

សិក្សាបណ្ណាល័យ មជ្ឈមណ្ឌលគាំពារទិសវិជ្ជាជីវៈ រោងពុម្ព បន្ទប់អនាម័យ អណ្តូងទឹក ។ល។ ដែលមាន តម្លៃសរុបប្រមាណ ២.២៣៦.០០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

១-លោក TEZUKA KOJI ប្រធានអង្គការ JSRC

២-លោក IZAKI OSAMU អនុប្រធានអង្គការ JSRC

៣-លោក TANAKA MASAO ជំនាញការរោងពុម្ព JSRC

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាល ប្រចាំ រាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ១២០ អនក្រ.តត

### ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលខេត្តកំពង់ចាម

### សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គការក្រៅរដ្ឋាភិបាល និងសប្បុរសជន ដែលបាន បរិច្ចាគថវិកា ជួយកសាងអាគារសិក្សា នៅក្នុងខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម :

១-អង្គការ វ៉េដបាណា កម្ពុជា ជួយកសាងអាគារសិក្សា ០៣ខ្នង នៅស្រុកព្រៃឈរ អស់ទឹកប្រាក់សរុបចំនួន ៣៧.២៨៩,១២ ដុល្លារអាមេរិក ។

២-លោក YOSHIHITO KOJIMA ប្រធានក្រុមហ៊ុន MITSUBISHI CORPORATION ជួយកសាងអគារសិក្សាមួយខ្នង នៅស្រុកបាធាយ ចំណាយអស់ទឹកប្រាក់ចំនួន ៣៣.០០០ ដុល្លារអាមេរិក ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យ លេខ ១២១ អនក្រ.តត
## ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ០៤រូប ដែលបានបរិច្ចាគថវិកា ជួយកសាងអាគារ០២ខ្នង នៅអនុវិទ្យាល័យ ជា ស៊ីម រក្សជ័យ ស្រុកបាភ្នំ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោមនេះ :

| | | | |
|---|---|---|---|
| ១-ឧបាសិកា | **ឯម ពាញ** | បរិច្ចាគថវិកា | ១០.០០០ US$ |
| ២-លោក | **ម៉ក់ ថ៏ន** | បរិច្ចាគថវិកា | ១០.០០០ US$ |
| ៣-លោកស្រី | **ស៊ុំ សាវ៉ាត** | បរិច្ចាគថវិកា | ១០.០០០ US$ |
| ៤-លោកស្រី | **ស៊ុំ សាវឿន** | បរិច្ចាគថវិកា | ១០.០០០ US$ |

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាល ខេត្តព្រៃវែង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ១២២ អនក្រ.តត

# ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនជប៉ុន ដែលបានបរិច្ចាគថវិកា ជួយកសាងសាលប្រជុំ បណ្ណាល័យ ក្លោងទ្វារ សួនច្បារ ជូនសាលាបឋមសិក្សា ទំនប់រលកចាស់ ក្នុងខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ អស់ទឹកប្រាក់ចំនួន ៨១.៥០០ ដុល្លារអាមេរិក ដូចមានរាយនាមខាងក្រោមនេះ :

១-លោកស្រី **អូសាណៃ មីអ៊ិកុ** ប្រធានអង្គការ JHP

២-លោក **នីតានី ហ៊ីដីអាគី** អនុប្រធានអង្គការ JHP

៣-ក្រុមហ៊ុនទូរទស្សន៍ TOKYO BROADCASTING SYSTEM INC (TBS)

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ១២៣ អនក្រ.តត
# ស្តីពី ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

មាត្រា ១ .- តែងតាំងលោក **នុយ រី** បច្ចុប្បន្នអនុប្រធាននាយកដ្ឋានសហប្រតិបត្តិការនយោបាយ និង ផ្នែកជំនាញ ទទួលបន្ទុក **Division I** នៃអគ្គនាយកដ្ឋានអាស៊ាន ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអាស៊ាន ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ១២៨ អនក្រ.តត
## ស្តីពី ការតែងតាំងអនុប្រធានគណៈកម្មាធិការ POW/MIA កម្ពុជា

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-យោងតាមសំណើរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

មាត្រា ១ .- តែងតាំងឯកឧត្តម សៀង ឡាប្រេស អនុរដ្ឋលេខាធិការ នៃក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អោយទទួលបន្ទុកបន្ថែមជា អនុប្រធានគណៈកម្មាធិការ POW/MIA កម្ពុជា ជំនួស ឯកឧត្តម អ៊ុង សាន ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ គណៈកម្មាធិការ POW/MIA កម្ពុជា គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

# អនុក្រឹត្យ លេខ ១២៥ អនក្រ.តត
## ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ
### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់របស់អភិបាលខេត្តតាកែវ

## សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនសប្បុរសជន ២២រូប ដែលបានបរិច្ចាគ ធនធាន ចូលរួមជួយកសាងសមិទ្ធផលសាធារណៈនានា នៅក្នុងវត្តសំរោងពន្លៃ ស្រុកអង្គរបុរី ខេត្តតាកែវ រួមមាន សាលាបឋមសិក្សា ០២ខ្នង អនុវិទ្យាល័យ ០៤ខ្នង សាលាបាលី ព្រះវិហារ កុដិ ក្លោងទ្វារ របង ។ល។ ដូចមានរាយនាម និង ទឹកប្រាក់ខាងក្រោមនេះ :

ក-មេដាយមាស ស្ថាបនាជាតិ :

| | | |
|---|---|---|
| ១-លោក សាយ សុផលា | ទឹកប្រាក់ | ១១.០០០ US$ |
| ២-អ្នកស្រី ចាន់ ឡុញ | ទឹកប្រាក់ | ១១.០០០ US$ |
| ៣-ឯកឧត្តម ហេ ភាន់ | ទឹកប្រាក់ | ១១.០០០ US$ |
| ៤-លោកជំទាវ ហេ ភាន់ | ទឹកប្រាក់ | ១០.៣៥០ US$ |

ខ-មេដាយប្រាក់ ស្ថាបនាជាតិ :

| | | |
|---|---|---|
| ១-លោក ង៉ូវ ឈឹវ | ទឹកប្រាក់ | ៥.១០០ US$ |
| ២-លោក ហ៊ី ប៉ូទី | ទឹកប្រាក់ | ៥.១០០ US$ |
| ៣-លោក អ៊ឹង លាង | ទឹកប្រាក់ | ៥.១០០ US$ |
| ៤-អ្នកស្រី សាយ សុផា | ទឹកប្រាក់ | ៥.១០០ US$ |

គ-មេដាយ សំរិទ្ធ ស្ថាបនាជាតិ :

| | | |
|---|---|---|
| ១-ឧបាសិកា ចេង លឹម | ទឹកប្រាក់ | ៤.៦០០ US$ |
| ២-លោកឧកញ៉ា យូ សាន្ត | ទឹកប្រាក់ | ៣.៦០០ US$ |
| ៣-លោក អ៊ូ ឆេង | ទឹកប្រាក់ | ២.០០០ US$ |
| ៤-លោក ម៉ី អ៊ឹម | ទឹកប្រាក់ | ២.០០០ US$ |
| ៥-ឧបាសិកា នួន គាត | ទឹកប្រាក់ | ៣.៥០០ US$ |
| ៦-លោក ស៊ុន សាខន | ទឹកប្រាក់ | ១.៥០០ US$ |
| ៧-ឧបាសិកា អ៊ុន ញ៉ា | ទឹកប្រាក់ | ២.០០០ US$ |

| | | | |
|---|---|---|---|
| ៨-លោក | ស៊ុន សុខន | ទឹកប្រាក់ | ១.៥០០ US$ |
| ៩-លោក | ជា ខនសេខ | ទឹកប្រាក់ | ១.៦០០ US$ |
| ១០-ឧបាសិកា | ឡេង អម | ទឹកប្រាក់ | ៣.០០០ US$ |
| ១១-ឧបាសិកា | ឡេង ម៉ែត | ទឹកប្រាក់ | ៣.០០០ US$ |
| ១២-ឧបាសិកា | ប៉ោក លាង | ទឹកប្រាក់ | ១.២០០ US$ |
| ១៣-ឧបាសិកា | ឱុយ អេង | ទឹកប្រាក់ | ១.០០០ US$ |
| ១៤-ឧបាសិកា | ឡេង អឿង | ទឹកប្រាក់ | ១.០០០ US$ |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ១២៦ អនក្រ.តត
# ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មន្ទីរអប់រំ យុវជន និងកីឡា ខេត្ត កំពង់ធំ

## សំរេច

**មាត្រា ១ .-** ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនអង្គការក្រៅរដ្ឋាភិបាល ដែលបានធ្វើអំណោយជាអាគារសិក្សា និងសំភារៈសិក្សាជូនប្រជាពលរដ្ឋ ក្នុងខេត្ត កំពង់ធំ ដូចមានរាយនាម និង ចំនួនទឹកប្រាក់អំណោយ ខាងក្រោមនេះ :

១-អង្គការ យូនីសែហ្វ ស៊ីដា : ៦២០.០៦៥ ដុល្លារអាមេរិក
២-អង្គការ អា-ប៉េ-អេស : ១១០.០០០ ដុល្លារអាមេរិក
៣-អង្គការ ទស្សនៈពិភពលោក : ៦០.០០០ ដុល្លារអាមេរិក
៤-អង្គការ ការីតាស : ២០.០០០ ដុល្លារអាមេរិក
៥-អង្គការ អាដ្រា : ១៦.០០០ ដុល្លារអាមេរិក
៦-អង្គការ ម៉េឌូឌិស ប៉េរីកម្ពុជា : ១៤.០០០ ដុល្លារអាមេរិក

មាត្រា២ .- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា និង អភិបាលខេត្ត កំពង់ធំ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ១២៧ អនក្រ.គត
## ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែល ប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រតិភូរាជរដ្ឋាភិបាល ប្រចាំរាជធានីភ្នំពេញ

### សំរេច

មាត្រា ១ .- ត្រូវបានប្រគល់ មេដាយមាសស្ថាបនាជាតិ ជូនលោកឧកញ៉ា សោ សេរីមុន្នី ហៅ យ៉ាត ដែលបាន បានបរិច្ចាគធនធានផ្ទាល់ខ្លួន ចំនួន ៥០.០០០ ដុល្លារអាមេរិក សំរាប់ជួយស្តារ និងកសាង ហេដ្ឋា រចនាសម្ព័ន្ធ រាជធានីភ្នំពេញ ។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

**អនុក្រឹត្យ លេខ ១២៨ អនក្រ.តត**

**ស្តីពី ការជូនមេដាយ ស្ថាបនាជាតិ**

***

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សំរេច**

**មាត្រា ១ .-** ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក **តេស៊ូកា ខូជី** ប្រធានអង្គការ JSRC ដែលបានឧបត្ថម្ភថវិកាជួយទ្រទ្រង់សាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម សរុបទឹកប្រាក់ ចំនួន ៨៥.០០០ ដុល្លារអាមេរិក ក្នុងមួយឆ្នាំ ។

**មាត្រា២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និងកីឡា ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យ លេខ ១២៩ អនក្រ.តត
## ស្តីពី ការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ

### សំរេច

មាត្រា ១ .- តែងតាំងលោក សោម សុគន្ធ ជាប្រធាននាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ នៃក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យ លេខ ១៣០ អនក្រ.តត
## ស្តីពី ការតែងតាំងមន្ត្រីរាជការ

* * *

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ.០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ

**សំរេច**

មាត្រា ១ .- តែងតាំងលោក ឡើង ឈៀង ជាសាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ របស់ក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ១៣១ អនក្រ.តត
# ស្តីពី ការតែងតាំងមន្ត្រីរាជការ

* * *

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

**សំរេច**

មាត្រា ១ .- តែងតាំង :

-លោក នុត សាខន ជាប្រធាននាយកដ្ឋានព្រៃព្រសាស្ត្រ

-លោក ស៊ុំ ទ៉ា ជាប្រធាននាយកដ្ឋានបច្ចេកទេសសេដ្ឋកិច្ច និងផ្សព្វផ្សាយ នៃក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

★★★

# អនុក្រឹត្យ លេខ ១៣២ អនក្រ.តត

## ស្តីពី ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ នស / រកម / ០១៩៦ / ១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និង នេសាទ

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

## សំរេច

មាត្រា ១ .- តែងតាំង លោក ឡោ រស្មី ជាសាលកវិទ្យាធិការរង សាកលវិទ្យាល័យ ភូមិន្ទកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

**ហ៊ុន សែន**

## ២-សេចក្តីសំរេច

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

**សេចក្តីសំរេច លេខ ៣៨ សសរ**

**ស្តីពីការបង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀន**

**ឆ្លងកាត់ព្រំដែនថ្នាក់ខេត្ត**

* * *

**រាជរដ្ឋាភិបាលកម្ពុជា**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ នស / រកត / ០៩៩៥ / ៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

-បានឃើញអនុក្រឹត្យ លេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

-យោងតាមតំរូវការចាំបាច់របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**សំរេច**

**ប្រការ ១ :** បង្កើតគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនឆ្លងកាត់ព្រំដែនថ្នាក់ខេត្តមួយ នៅខេត្តកោះកុង ។

**ប្រការ ២ :** គណៈកម្មាធិការនេះមានសមាសភាពដូចតទៅ :

| | |
|---|---|
| -អភិបាលខេត្ត កោះកុង | ប្រធាន |
| -តំណាងអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិកអចិន្ត្រៃយ៍ |
| -តំណាងស្នងការដ្ឋាននគរបាលខេត្តកោះកុង | សមាជិក |
| -តំណាងទីចាត់ការគយ និង រដ្ឋាករ | សមាជិក |
| -តំណាងកងនាវាចរខេមរភូមិន្ទមូលដ្ឋានសមុទ្រ | សមាជិក |
| -តំណាងតំបន់ប្រតិបត្តិការសឹករងខេត្ត | សមាជិក |
| -តំណាងបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត | សមាជិក |

តំណាងកម្មវិធីត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ របស់អង្គការសហប្រជាជាតិ (UNDCP) ជាអ្នកផ្តល់យោបល់ ។

អភិបាលខេត្ត ជាអ្នកប្រតិបត្តិ (Focal person) ។

សមាជិកនៃគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំការងារតាមការអញ្ជើញរបស់ប្រធាន ។

**ប្រការ ៣ :** គណៈកម្មាធិការនេះមានភារកិច្ចដូចតទៅ :

-សហប្រតិបត្តិការ និង សម្របសម្រួលជាទូទៅនូវវិធានការ ប្រយុទ្ធប្រឆាំងគ្រឿងញៀន រវាងខេត្តកោះកុង នៃព្រះរាជាណាចក្រកម្ពុជា និងសមភាគីខាងខេត្តត្រាតនៃ ព្រះរាជាណាចក្រថៃ ។

-ធ្វើអោយកាន់តែប្រសើរឡើងនូវការផ្លាស់ប្តូរពត៌មានតាមព្រំដែនរាល់បញ្ហាដែលពាក់ព័ន្ធនឹងការផលិតគ្រឿងញៀន ការចរាចរគ្រឿងញៀន សារធាតុផ្សំគ្រឿងញៀន និងការប្រើប្រាស់ គ្រឿងញៀន ។

-បង្កើតនីតិវិធីរួមមួយរស់រាប់ធ្វើអោយមានទំនាក់ទំនង ខាងបណ្តាញផ្លាស់ប្តូរ ប្រមូលពត៌មានជាតិនៃប្រទេសទាំងពីរ ។

-បង្កើតអោយទំនាក់ទំនងជិតស្និទ្ធរវាងមន្រ្តីក្នុងវិស័យផ្សេងៗ នៃការត្រួតពិនិត្យគ្រឿងញៀន និងពិភាក្សាលើផលប្រយោជន៍រួមនៅតាមព្រំដែន នៃប្រទេសទាំងពីរ ។

-ជួបជាមួយភាគីខេត្តត្រាតយ៉ាងទៀងទាត់ ដើម្បីពិភាក្សាអំពីយុទ្ធសាស្រ្តសកម្មភាពប្រតិបត្តិការ និង ពង្រឹងកិច្ចសហប្រតិបត្តិការ ។

**ប្រការ ៤ :** គណៈកម្មាធិការនេះមានទីតាំងនៅខេត្តកោះកុង ។

**ប្រការ ៥ :** គណៈកម្មាធិការនេះមាន លេខាធិការដ្ឋានមួយជាសេនាធិការក្នុងភារកិច្ចដឹកនាំ គ្រប់គ្រង លើកផែនការ តាមដាន វាយតំលៃការអនុវត្តន៍ការងារប្រយុទ្ធប្រឆាំងគ្រឿងញៀននៅក្នុងខេត្ត ។ សមាជិកអចិន្ត្រៃយ៍ អ.ជ.ប.គ.ញ. ជាអ្នកទទួលខុសត្រូវ ។ ភារកិច្ចរបស់លេខាធិការដ្ឋាននេះ អាស្រ័យដោយ គណៈកម្មាធិការ ជាអ្នកកំណត់ ។

**ប្រការ ៦ :** បទបញ្ញត្តិ ទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** រដ្ឋមន្រ្តីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្រ្តី សហរដ្ឋមន្រ្តីក្រសួងមហាផ្ទៃ រដ្ឋមន្រ្តីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្រ្តីក្រសួងការពារជាតិ អគ្គលេខាធិការ នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មេបញ្ជាការកងនាវាចរខេមរភូមិន្ទមូលដ្ឋានសមុទ្រ ទីចាត់ការគយ និងរដ្ឋាករ អភិបាលខេត្តកោះកុង ស្នងការនគរបាលខេត្ត តំបន់ប្រតិបត្តិការសឹករងខេត្ត មេបញ្ជាការកងរាជអាវុធហត្ថខេត្ត និងគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្រ្តី

ហត្ថលេខានិងត្រា

ហ៊ុន សែន

★★★

ភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

## សេចក្តីសំរេច លេខ ៣៩ សសរ

## ស្តីពីការ ផ្ទេរសិទ្ធិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## សំរេច

ប្រការ ១ : ផ្ទេរសិទ្ធិជូនឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រី ក្រសួងផែនការ ជា រដ្ឋមន្ត្រីស្តីទី នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជំនួសឯកឧត្តម គាត ឈន់ រដ្ឋមន្ត្រីស្តីទី នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដែលត្រូវទៅបំពេញបេសកកម្មនៅក្រៅប្រទេស ចាប់ពីថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ១៩៩៩ រហូតដល់ឯកឧត្តម វិលត្រឡប់មកមាតុប្រទេសវិញ ។

ប្រការ ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ខេត្ត ក្រុង និង ឯកឧត្តម ឆាយ ថន ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ការងាររបស់ក្រសួង
## ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ ១៩៩៩

**ប្រកាសលេខ ៤៨៨ ឧក/ប្រក**

* * *

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

-បានឃើញលិខិត លេខ ២៦០៩ / ៩៨ ក.វ.ក. ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

-បានឃើញលិខិត លេខ ៥៣៣ ប.ស្ថ ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ១៩៩៩ របស់ក្រសួងបរិស្ថាន ។

-បានឃើញលិខិត លេខ ៣៥៦៦ ធ.ត.ស. ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់សាលាក្រុងភ្នំពេញ ស្តីពីការអនុញ្ញាតអោយបើកទីតាំងរោងចក្រកាត់ដេរ ។

-យោងពាក្យស្នើរបស់ក្រុមហ៊ុន យូ ឆេង ហ្គាមេនស៍ ចុះថ្ងៃទី៣០ ខែ មីនា ឆ្នាំ ១៩៩៩ ។

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយក្រុមហ៊ុន យូ ឆេង ហ្គាមេនស៍ (YOU CHENG GARMENTS Co., LTD) តំណាងដោយលោក JI ZHANKUN សញ្ជាតិ ចិន ភេទប្រុស អាយុ ៤៨ ឆ្នាំ អាស័យដ្ឋាន West Gart Shimen Town Towngxing , Zhejiang , CHINA , កាន់លិខិតឆ្លងដែនលេខ CHN P 142305132 ចុះថ្ងៃទី 20 .3.1996 បង្កើត " រោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា " រោងចក្រកាត់ដេរ យូ ឆេង ហ្គាមេនស៍ " មានទីតាំងស្ថិតនៅដីឡូត៍លេខ ១៩២៦ ផ្លូវជាតិ លេខ២ សង្កាត់ ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ : ការបង្កើតរោងចក្រនេះ ក្រុមហ៊ុនត្រូវធ្វើទៅតាមប្លង់ និងគំរោងសិក្សាលទ្ធភាពបង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាការពារបរិស្ថាន និងគុណភាពផលិតផល ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ ជូនក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ។

ប្រការ ៤ : រោងចក្រនេះត្រូវបានអនុញ្ញាតអោយ “កាត់ដេរសំលៀកបំពាក់” នៅតាមគំរូ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៥ : រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

ប្រការ ៦ : ក្រុមហ៊ុនត្រូវលើកបង្ហាញ “ផ្លាកឈ្មោះរោងចក្រ” របស់ខ្លួននៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

ប្រការ ៧ : ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយដែលមានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

ប្រការ ៨ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ និងប្រធានក្រុមហ៊ុន យូ ឆេង ហ្គាមេនស៍ ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

ប្រការ ៩ : ប្រកាសនេះមានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ហត្ថលេខានិងត្រា

ស៊ុយ សែម

★★★